# កម្ពុជសុរិយា

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ណារក្ស នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេវសត្ថា ស៊ូ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| មហា ខឹម - ណាគ្រី | និទានសុភាសិត ........................ | ៤៨១ |
| លោកយោគ្យត្រី ម៉ៅ-ម៉ុ | ល្បែងផ្សេងៗ ........................ | ៤៨៥ |
| លោក ភិយ-ប៊ុក ក្រមការ | សុភាសិតភាគទី២ ........................ | ៤៩៣ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌា (តមក) .. | ៥០០ |
| — | ស័ព្ទបារាំងប្រែជាខ្មែរ (តមក) .............. | ៥០៨ |
| អ្នកឧកញ៉ា នូ-កន | រឿងសាមកុក (តមក) .................... | ៥១៥ |
| អ្នកឧកញ៉ា ព្រះឃ្លាំងឯង | រឿង «កោតក្របកុមារ» (តមក) ......... | ៥២៥ |
| ***ផ្នែកសាសនា*** | | |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | គម្ពីរអាសីវិស (តមក) .................... | ៥៣១ |
| មហាឌឹម - ណាគ្រី | មុនីសុភាសិត (តមក) .................... | ៥៤១ |
| ***កំណត់ហេតុប្រវត្តិការណ៍*** | | |
| ព្រះទេវសត្ថា ស៊ូ-ហាយ | ពិធីស្រោចទឹក លោកគ្រូអាចារ្យ ហង្ស-ប៊េង | ៥៤៧ |
| ក្រសួងឃោសនាការ | អំពីការតាំងបើកវិហារថ្មី (តមក) .......... | ៥៥៤ |

ឆ្នាំទី ២០ — លេខ ៧ ខែកក្កដា ឆ្នាំ ១៩៤៨ — ដំឡៃជាវ ១ ឆ្នាំ ៩៦ រៀល ។

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî NHOK-THÈM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Satthā So-HAY membre de la Commission du Tripitaka

# TABLE DES MATIÈRES

## Partie littéraire :


| | | page |
|---|---|---|
| Mahâ OM-NAGRY | Nidânasubhasit.................. | 481 |
| M. le YOKBAT MAU-MEY | Jeux populaires Cambodgiens....... | 485 |
| M. Ray-Buc kramkar (I.B.) | Proverbes et maximes Tome II .... | 497 |
| Luong Nibandhamantrî NHOK-THÊM | Histoire sommaire de l'Inde (suite).. | 500 |
| —id— | Recueil de Dictons et devises français (suite)........................ | 508 |
| Neak Oknha Nou-Kân | Histoire de « Sam Kok » (suite)..... | 515 |
| Neak Oknha Nong | Bhog kulkumar (en vers) (suite).... | 525 |


## Partie religieuse:


| | | |
|---|---|---|
| Luong Nibandhamantrî NHOK-TEÈM | Lumière de l'Asie (suite) .......... | 531 |
| Maha OM-NAGRY | Munisubhâsit (suite)...... ...... | 540 |


## Notes et chroniques


| | | |
|---|---|---|
| Vén. Brah Debasatthâ So-Hay | Cérémonie de l'ondoiement du Vén. Hang-Péng......... ....... .... | 548 |
| Ministère des cultes | Nomination des nouveaux chau Adhikar (suite)................ | 554 |


21e Année: N° 7 Juillet 1949 — Prix d'abonnement: 96$00 par an.

## និទានសុភាសិត

"ខ្លាពឹងព្រៃ ព្រៃពឹងខ្លា"

(ព្យគ្ឃជាតក តិកនិបាត)

# មហាឱម-ណាគ្រី

ឃុំស្វាយពោ ស្រុកសង្កែ ខេត្តបាត់ដំបង ប្រែរៀបរៀង

---

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រប់គ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វឧប្បត្តិជារុក្ខទេវតាមួយអង្គ គង់នៅជាយព្រៃធំមួយ ។ មានរុក្ខទេវតាមួយអង្គដទៃទៀត នៅទីដើមឈើដែលធំបំផុតក្នុងព្រៃជិតវិមានរបស់ព្រះពោធិសត្វ ។

ក្នុងព្រៃនោះ មានរាជសីហ៍និងខ្លាធំអាស្រ័យនៅផង ព្រោះដូច្នោះ ទើបមិនមានមនុស្សណា ហ៊ានទៅធ្វើស្រែចំការក្នុងទីជិតនោះ ឬកាប់ដើមឈើក្នុងព្រៃនោះឡើយ ព្រោះខ្លាចសត្វទាំងពីរនោះបៀតបៀន ។ សត្វទាំងពីរនោះចាប់ម្រឹគជាតិផ្សេងៗ ស៊ីជាអាហារ ចោលសាច់និងអវយវៈដែលស៊ីសេសសល់ទុកសំណល់ក្នុងទីនោះៗ ហើយរកស៊ីទៀតទៅ ។ ព្រៃនោះមានក្លិនផ្អាបផ្អេះស្អុយអសោចិ៍ទៅដោយខ្មោចអសុកនៃម្រឹគជាតិ ។

គ្រានោះ រុក្ខទេវតាដែលនៅទីដើមឈើធំ ជាអ្នកខ្លៅល្ងង់មិនស្គាល់ឲ្យយល់ដល់ហេតុការណ៍ ថ្ងៃមួយបាននិយាយនឹងព្រះពោធិសត្វថា "សំឡាញ់! ព្រៃនេះមានក្លិនស្អុយអសោចិ៍ពន់ពេកណាស់ ព្រោះតែរាជ-

សីហ៍នឹងខ្លាធំជាហេតុ យើងនឹងដេញកាត់ឲ្យរត់ទៅកុំឲ្យនៅតទៅទៀត!" ។ ពោធិសត្វពោលឃាត់ថា "នែសំឡាញ់! វិមានរបស់យើងតាំងនៅបាន ព្រោះអាស្រ័យសត្វទាំងពីរនោះ បើយើងដេញកាត់ទៅហើយ វិមានយើងមុខជាវិនាសមិនខាន មនុស្សទាំងឡាយកាលមិនឃើញដានជើងរាជសីហ៍នឹងខ្លាធំ ក៏នឹងនាំគ្នាមកកាប់ឈើរើព្រៃ ដីកកាស់ឲ្យស្រឡះទៅជាវាល នឹងធ្វើស្រែចំការមិនខាន អ្នកកុំចូលចិត្តយ៉ាងនេះឡើយ!" ។

កាលព្រះពោធិសត្វថ្លែងហេតុយ៉ាងនេះហើយ ទេវតាឆោតខ្លៅនោះមិនយកចិត្តទុកដាក់ធ្វើតាមសោះ ថ្ងៃមួយបានសំដែងរូបារម្មណ៍ដ៏ធំពន្លឹកគួរខ្លាច បន្លាចលង្គ្រហឹមគម្រាម ដេញរាជសីហ៍នឹងខ្លាធំឲ្យរត់បាត់អស់ទៅ ។

មនុស្សទាំងឡាយ កាលមិនឃើញដានជើងរបស់សត្វទាំងពីរនោះ ក៏សំគាល់ថារាជសីហ៍នឹងខ្លាធំទៅនៅព្រៃដទៃហើយ ទើបនាំគ្នាកាប់គាស់ដើមឈើក្នុងព្រៃអស់ជាច្រើន ។ រុក្ខទេវតានោះ លុះឃើញព្រឹត្តិការណ៍ដូច្នោះកើតឡើង ទើបចូលទៅរកព្រះពោធិសត្វហើយនិយាយថា "សំឡាញ់! ខ្ញុំមិនបានធ្វើតាមពាក្យរបស់អ្នក ដេញសត្វទាំងពីរនោះឲ្យរត់អស់ទៅ ឥឡូវពួកមនុស្សដឹងថាសត្វទាំងនោះមិននៅ ទើបនាំគ្នាចូលទៅកាប់គាស់ឈើក្នុងព្រៃអស់ជាច្រើន បើយ៉ាងនេះ តើយើងគិតដូចម្ដេចទើបស្រួល!" ។ ព្រះពោធិសត្វបានពន្យល់ដឹកនាំប្រាប់ឧបាយថា

"ឥឡូវសត្វទាំងពីរនោះ នៅនៅក្នុងព្រៃឯណា៎ អ្នកទៅបបួលវាឲ្យត្រឡប់មកវិញចុះ" ។ រុក្ខទេវតាក៏ចូលទៅក្នុងព្រៃនោះតាមពាក្យពោធិសត្វ អង្គុយផ្ទង់អញ្ជលីខាងមុខសត្វទាំងពីរ ហើយអង្វរករឲ្យត្រឡប់ទៅនៅព្រៃដដែលវិញ ។ សត្វទាំងពីរនោះ ទោះបីទេវតាអង្វរយ៉ាងណាៗក្តី ក៏បដិសេធយ៉ាងដាច់ខាតថា "អ្នកចូរទៅចុះ យើងមិនទៅទេ" រុក្ខទេវតាទាល់គំនិត ក៏ត្រឡប់មកកាន់ព្រៃជាកន្លែងដើមរបស់ខ្លួនវិញ ។ មនុស្សទាំងឡាយ ក៏នាំគ្នាដីកគាស់កាប់រំលើងរំលំដើមឈើរហូតអស់ព្រៃ មិនយូរប៉ុន្មានក៏ធ្វើផែនដីនោះឲ្យទៅជាស្រែចំការកសិកម្មអស់ទៅ ។

## គតិរបស់រឿង

រឿងនោះពន្យល់ឲ្យដឹងថា " ខ្លាពឹងព្រៃ ព្រៃពឹងខ្លា "
ខ្លានៅព្រោះព្រៃបិទ ព្រៃសណ្ឋិតព្រោះខ្លានៅ
ដីត្រជាក់ព្រោះស្មៅ ស្មៅលូតលាស់ព្រោះដីល្អ ។
អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ
អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅពឹងសំប៉ាន ។
រាជការបានប្រាក់ខែ ក៏ព្រោះតែរាស្ត្របង់ពន្ធ
រាស្ត្រសុខចាកអសន្ត ព្រោះរាជការជួយការពារ ។
ហេតុនេះត្រូវស្ម័គ្រស្មោះ ជួយសង្គ្រោះគ្នានឹងគ្នា
ទើបបានសុខសាន្តជា អស់វេលាយូរយារអើយ!!! ។

# សុភាសិត

ការដក់អាភៀនការញៀនកញ្ឆា ការផឹកសុរាហ៊ឺហាហ៊ឹកហ៊ាក់
ការលេងល្បែងភ្នាល់បៀរប៉ោឡុកឡាក់ ឥត្ថីធុត្តៈការលេងស្រីញី ៗ
ការដើរលេងយប់យឺតយូរហួសយាម ការជាប់ទាក់ទាមសេពគប់សម្ភី
នឹងមនុស្សអាក្រក់លាមកផឹកស៊ី ទាំងនេះនាំវិនាសអន្តរធាន ៗ

**មហា ទម - ណាត្រី**

# ល្បែងផ្សេងៗ

# របស់លោកយោក្បត្រ មៅ ម៉ុ

## ក្រសួងមហាផ្ទៃ ភ្នំពេញ

"រង្វាន់លេខពីរ"

---

ល្បែងទាំងនេះ កើតមានជាយូរយារណាស់មកហើយ គឺល្បែងលេងពួន, លោតអន្ទាក់, លាក់កន្សែង, ចាប់កូនខ្លែង, ហ៊ឹង ប៉ុកយកូនប៉ែង, លេងអង្គញ់, បោលឈូង, ទីងទាញព្រ័ត្រ ។ ល ។

ល្បែងទាំងនេះ មានលេងរើសពេលខ្លះ មិនរើសពេលខ្លះ មានលេងបានតែក្មេងៗខ្លះ មានលេងសុទ្ធតែមនុស្សចាស់ៗខ្លះ ចែកចេញជាពីរចំណែក :

១) ល្បែងលេងពួន, ចាប់កូនខ្លែង, លោតអន្ទាក់, លាក់កន្សែង, កូនប៉ែង មានលេងច្រើនតែកូនក្មេង តតមានរើសពេលវេលាទេ ឲ្យតែយប់ខែភ្លឺចេះតែលេងបានទាំងអស់ វៀរលែងតែកូនប៉ែង ១ ចេញ ព្រោះល្បែង ១ នេះលេងបានតែពេលថ្ងៃ ហើយក្មេងដែលលេងនោះទៀតច្រើនតែក្មេងឃ្វាលក្របី នាំគ្នាលេងនៅឱកាសឃ្វាលក្របី ។

២) ល្បែងបោលឈូង, អង្គញ់, ទាញព្រ័ត្រ, ច្រើនតែមនុស្សចាស់លេង ក្នុងឱកាសចូលឆ្នាំថ្មី កំណត់កាលដែលលេងនោះ ៣ យប់ ៣ ថ្ងៃ ចួនកាលលេងនៅក្នុងភូមិ ចួនកាលលេងក្នុងវត្តអារាម ។

ល្បែងទាំងនេះខ្ញុំសូមអធិប្បាយជូនតាមមាតិកាដូចខាងក្រោមនេះ ៖

ក ) **ល្បែងលេងពួន** – ( លេងនៅខែត្រពៃវែង ) កាលខ្ញុំនៅជាកុមារតូចនៅឡើយ ខ្ញុំធ្លាប់លេងនឹងគេដែរ, នៅពេលយប់ខែភ្លឺទទួលទានបាយរួចហើយ ក្មេងប្រុសស្រីដើរបបួលគ្នាបាន ១០ នាក់ផ្ដើមគ្នាលេងពួន មានក្មេងម្នាក់នៅចាំទី ក្មេងឯទៀតទៅពួន ។ មុននឹងទៅពួន ក៏ឈរដំកង់គ្នាជុំវិញ, មានក្មេងម្នាក់ឈរនៅចំកណ្ដាល ជាអ្នកចាត់ចែងរើសអ្នកចាំទី ក្មេងនោះយកដៃទៅចង្អុលដើមទ្រូង ក្មេងឯទៀតដែលឈរជុំវិញខ្លួននោះ ហើយថាជាពាក្យដូច្នេះ "ត្រាយត្រកត្រាយក្រេង ប៉ាក់ក្រអេងណាំនៀក ប៉ាក់កាឌៀកខុយយ៉ា ប៉ាកក្រយាយោយទុច" ពាក្យចុងបង្អស់ទៅត្រូវត្រឹមក្មេងណា ក្មេងនោះត្រូវទៅពួន ៗ

ក៏ថាដដែល ៗ ទាល់តែគ្រប់គ្នា នៅសល់ក្មេងណា ក្មេងនោះត្រូវនៅចាំទី ៗ ឯទីនោះ គឺគូសដីវង់មូលជុំវិញ សន្មតថាជាទីរបស់វា ហើយក្មេងអ្នកចាំទី តាំងយកដៃបិទមុខ ដើម្បីសញ្ញាឲ្យក្មេងឯទៀតទៅពួន ៗ លុះ ១ស្របក់វាស្រែកថា "បើកគ្រប់បាយ" ក្មេងដែលពួនតាំងលាក់ខ្លួនសម្ងំស្ងាត់ជ្រៀប ពុំហ៊ានមាត់កឲ្យឮទេ ខំដើរលបៗទន្ទបទៅរកចូលទី កុំឲ្យក្មេងចាំទីឃើញ តែវាឃើញវាចាប់ញៀចស៊ីកត្រៀក ម៉្លោះហើយក្មេងៗ មានសេចក្ដីភិតភ័យខ្លាំងណាស់ ៗ ចំណែកក្មេងអ្នកចាំទី ក៏ប្រឹងគយគន់មើលគ្រប់ច្រកល្ហកផ្ទះ ក្រែងឃើញក្មេង

ដែលពួន នឹងគាលចាប់ញៀច បើចាប់ញៀចបានម្នាក់ៗ មានចិត្តត្រេកអរណាស់ ព្រោះសង្ឃឹមថា ពេលក្រោយនឹងបានទៅពួននឹងគេ បើញៀចមិនបានទេ ដល់ពេលពួនលើកក្រោយ គេក៏ឲ្យរកនៅតែចាំទីរហូតដល់ទៅឈប់លេង ។

**ល្បែងលេងពួន ចប់តែប៉ុណ្ណេះ**

ខ ) **ល្បែងលោតអន្ទាក់** — ល្បែងនេះ កាលខ្ញុំនៅពីក្មេង ខ្ញុំធ្លាប់លេងនឹងគេដែរ, ដើមដំបូង យកក្មេងពីរនាក់ឲ្យកាន់ដៃគ្នា អង្គុយបោង-ហោងបែរមុខរកគ្នា ក្មេងឯទៀតជាអ្នកលោត ។ មួងអន្ទាក់នោះខ្ពស់បន្តិចបេះតែខ្ពស់ៗទៅ បើក្មេងណាលោតទៅទាក់នឹងដៃក្មេងដែលធ្វើអន្ទាក់នោះ ត្រូវឈប់លោតតទៅទៀត ក្មេងណាដែលគាបលោតបានខ្ពស់នោះ ត្រូវបេះតែលោតៗទៅ ។ ល្បែងនេះ បេះតែឆ្លាស់គ្នាធ្វើអន្ទាក់ម្ដងម្នាក់ រហូតទៅទល់នឹងឈប់លេង ។ ល្បែងនេះសឲ្យឃើញថា ជាធើហាត់បំរើនកំពស់ ។

**ល្បែងលោតអន្ទាក់ ចប់តែប៉ុណ្ណេះ**

គ ) **ល្បែងលាក់កន្សែង** — ល្បែងនេះ ខ្ញុំធ្លាប់លេងដែរ កាលនៅពីកុមារ — របៀបលេងមានច្រើនគ្នា នាំគ្នាអង្គុយជុំកង់ជុំវិញ ក្មេងម្នាក់ជាអ្នកកាន់កន្សែងដើរលាក់ ។ ឯកន្សែងនោះ ជួនកាលយកក្រមាខ្លួតទឹកឆ្បលធ្វើជាដុំ ១ ហើយកាន់ដើរជុំវិញក្មេងដែលអង្គុយជុំកង់នោះ លួមតែក្មេងទាំងនោះអង្គុយគេចត្រចៀក យកកន្សែងទៅលាក់ពីក្រោយខ្នង

ហើយដើរមួយជុំទៅទៀត ក្មេងដែលគេលាក់កន្សែងពីក្រោយខ្នង បើដឹងខ្លួន ក៏យកដៃស្ទាបពីក្រោយខ្នង បើឃើញត្រូវរើសយកកន្សែង ដើរលាក់មួង ។ បើអ្នកលាក់កន្សែងត្រឡប់មករើសយកកន្សែងបានពីក្រោយខ្នងក្មេងណា ត្រូវគក់នឹងល្បឹរកន្សែងត្រង់កណ្ដាលខ្នងក្មេងនោះ ១ គុក ហើយកាន់ដើរលាក់តទៅទៀត ។

ល្បែងនេះ សឲ្យឃើញថាជាល្បែង ១ សម្រាប់ឲ្យមានស្មារតីប្រុងខ្លួនជានិច្ច កុំឲ្យគេលួចយករបស់អ្វីទៅលាក់ក្បែរខ្លួន បើទុកជាគេយកមកលាក់ ក៏ឲ្យដឹងថាគេលាក់ ។

**ចប់ល្បែងលាក់កន្សែង តែប៉ុណ្ណេះ**

ឃ) **ល្បែងចាប់កូនខ្លែង** — ល្បែងនេះ គេលេងត្រាប់តាមសត្វខ្លែងដែលឆាបចាប់កូនមាន់, តែដែលហៅថាចាប់កូនខ្លែងទៅវិញ គឺជាពាក្យផ្ទុយគ្នានឹងចាប់កូនមាន់ ។

វិធីដែលនឹងលេង គឺក្មេងម្នាក់ដែលមានរូបមាឌធំមាំជាងគេ ធ្វើជាសត្វខ្លែង ។ ក្មេងម្នាក់ទៀតធំមាំជាងគេ ធ្វើជាមេមាន់ ហើយក្មេងឯទៀតធ្វើជាកូនមាន់ គោងចង្កេះខាគៗ គ្នាពីមេមាន់រហូតទៅក្រោយ ក្មេងដែលធ្វើជាខ្លែង តាំងរត់ឆ្វៀងខ្លួនរេចុះរេឡើង ធ្វើជាអកក្កាហានឆាបជុំវិញមេមាន់ ដើម្បីដណ្ដើមយកកូនមាន់ដែលគោងពីក្រោយ ឯមេមាន់ក៏ខំការពារពាដៃ ច្រានសត្វខ្លែងមិនឲ្យឆក់យកកូនបាន ។ ជួនកាលការពារឈ្នះ ជួនកាលក៏ការពារមិនឈ្នះ ខ្លែងដណ្ដើមយកកូនបានខ្លះទៅ ។

ល្បែងនេះ ជាវិធីហាត់ប្រាណឲ្យរហ័សរហួន ដើម្បីរក្សារបស់ទ្រព្យដែលគេបំរុងដណ្ដើមយក កុំឲ្យគេយកបាន ។

**ចប់ល្បែងជាប់ក្លួនខ្មែរ តែប៉ុណ្ណេះ**

ង) **ល្បែងកូនប៉ែង ឬ ហ៊ុង** — ល្បែងនេះ កាលខ្ញុំនៅពីក្មេងធ្លាប់បានលេងជាច្រើនដងណាស់ ព្រោះខ្ញុំបានទៅឃ្វាលក្របីនឹងគេដែរ ពួកក្មេងដែលលេងច្រើនតែក្មេងឃ្វាលក្របី ៗ ឯទីកន្លែងដែលលេងៗនៅកាលដែលឃ្វាលនោះ ៗ ប្រដាប់សម្រាប់លេងហ៊ុងនេះ គឺមានកូនប៉ែង ១ ប្រវែង ១ ចំអាម ហើយនឹងព្រនង់ ១ ប្រវែង ២ ហត្ថ ៗ របៀបលេងត្រូវចែកពួកគ្នាជា ២ ពួកឲ្យស្មើភាគគ្នា ទីកន្លែងលេង ត្រូវជីកដីធ្វើជារន្ធសណ្ឋានទ្រវែង ទំហំប៉ុនព្រនង់នោះ ហើយយកកូនប៉ែងទៅដាក់ទទឹងរន្ធនោះ រួចយកព្រនង់ឆ្កេះឲ្យលឿនទៅមុខ អ្នកឆ្កេះនោះ លុះឆ្កេះរួចហើយត្រូវយកព្រនង់ដាក់ទទឹងរន្ធវិញ ឯក្មេងពួកម្ខាងត្រូវឈរចាំចាប់ បើចាប់កូនប៉ែងបានត្រូវបោះទៅឲ្យត្រូវព្រនង់ដែលនៅលើរន្ធ បើបោះត្រូវៗឡើងមកឆ្កេះវិញ បើបោះមកមិនត្រូវ, អ្នកឆ្កេះដំបូង ត្រូវប៉ែងកូនប៉ែងទៅមុខទៀត ហើយយកដំបងមកគ្រវាសនៅរន្ធ បើកាលណាគេបោះកូនប៉ែងមក ត្រូវវាយផាត់ឲ្យត្រូវកូនប៉ែង ឲ្យឃ្លាតឆ្ងាយពីមាត់រន្ធចំនួនប្រវែង ១ ព្រនង់, បើឆ្ងាយជាងនេះ ត្រូវវាស់នឹងព្រនង់ហើយរាប់ បើបាន ១០ហើយ ត្រូវឈប់ប៉ែងទៅទៀត, បើខ្វះត្រូវប៉ែងឲ្យទាល់តែបានគ្រប់

ចំនួន ១០ លុះគ្រប់ ១០ហើយ ត្រូវយកកូនប៉ែងមកតែះនឹងព្រនង់ រាប់ថា មួយ, ពីរ, បី, . . . . . . . បើកូនប៉ែងធ្លាក់ត្រឹមចំនួនណា ត្រូវឈប់តែះត្រឹមណោះ ហើយក៏យកដំបងរាយកូនប៉ែងនោះ ឲ្យឆ្ងាយទៅមុខ, ឯពួកក្មេងម្នាក់ដែលចាញ់នោះចាំមើល បើឃើញកូនប៉ែងធ្លាក់ត្រឹមណា ត្រូវទៅរើសយកកូនប៉ែងនោះក្ដាប់ក្នុងដៃ ហើយរត់ស្រែកថា "ហ៊ឹង!" កុំឲ្យដាច់សំឡេង រត់សំដៅមករករន្ធ ដល់ហើយ យកកូនប៉ែងមកបោះដាក់នៅរន្ធ ។ បើដាច់សំឡេងនៅកន្លែងណា អ្នកម្នាក់ដែលឈ្នះ ត្រូវរាយកូនប៉ែងបន្តពីកន្លែងនោះទៅទៀត ចាប់អ្នកចាញ់ឲ្យហ៊ឹងម្ដងទៀត ដរាបទាល់តែមិនដាច់សំឡេង, រាយកូនប៉ែងឲ្យគ្រប់នឹងតែះ បើបាន ១ ត្រូវហ៊ឹងតែ ១, បើបានពីរត្រូវហ៊ឹង ២ ដង, រួចហើយផ្លាស់គ្នាលេងម្ដងម្នាក់ រហូតទៅទល់នឹងឈប់លេង ។

ល្បែងនេះ គេលេងសំរាប់បំបាត់ងងុយដេក នៅពេលដែលឃ្វាលគោ ក្របី ព្រោះស្មារតីកូនក្មេង តែនៅស្ងៀម ច្រើនតែងងុយដេក ម្ល៉ោះហើយនាំគ្នាលេងផង មើលគោ ក្របីផង ។

**ចប់ល្បែងកូនប៉ែង ឬ ហ៊ឹងតែប៉ុណ្ណោះ**

ល្បែងទាំងឡាយដែលបានពណ៌នាមកហើយនេះឯង ជាល្បែងសម្រាប់កូនក្មេងលេង ទាំងជាល្បែងមិនរើសពេល ។ តអំពីនេះ នឹងអធិប្បាយអំពីល្បែងសម្រាប់មនុស្សចាស់លេងតទៅទៀត ។

ល្បែងដែលមនុស្សចាស់លេងបាននោះ គឺល្បែងអង្គុញ - បោលឈូង - ទាញព្រ័ត្រ, ល្បែងទាំង ៣ មុខនេះ ក្មេងក៏លេងបាន មនុស្សចាស់ក៏លេងបាន តែច្រើនលេងក្នុងថ្ងៃចូលឆ្នាំ ៣ យប់ ៣ ថ្ងៃ លេងទទួលទេវតាថ្មី, ជួនកាលលេងក្នុងភូមិ ជួនកាលលេងក្នុងវត្ត ៗ ក្នុងល្បែងទាំង ៣ មុខនេះ សូមនិយាយតែល្បែងបោលឈូង នឹងទាញព្រ័ត្រ ដូចមានអធិប្បាយតទៅនេះ :

## ល្បែងបោលឈូង

ល្បែងនេះ មានលេងនៅខែត្រព្រៃវែង ខ្ញុំធ្លាប់លេងផ្ទាល់ខ្លួនខ្ញុំក្នុងឱកាសបុណ្យចូលឆ្នាំរាល់ឆ្នាំ, ដែលហៅថា ឈូង គឺគេយកសំពត់ឬក្រមាបត់មកមូរធ្វើជាដុំមូល រួចយកក្រមា ១ មករុំរេបចងពីក្រៅ ទុកបន្សល់ចុងជាយសម្រាប់យួរទៅមក ។ ល្បែងឈូងនេះ មានលេងជា ២ យ៉ាង ម្យ៉ាងហៅថា លេងឈូងបោល ម្យ៉ាងទៀតហៅថាលេងឈូងប្រៀង ៗ ឯរបៀបលេងមានប្រុសម្នាក់ ស្រីម្នាក់ដូចគ្នា ប៉ុន្តែប្លែកគ្នាត្រង់របៀបលេង ដូចខាងក្រោមនេះ :

## លេងឈូងបោល

លេងឈូងបោលនេះ អ្នកត្រូវលេងសុទ្ធតែឈរ ប្រុសម្នាក់ស្រីម្នាក់ ពួកខាងប្រុសបោះឈូងទៅឲ្យខាងស្រី បើខាងស្រីចាប់បានត្រូវបោល

ឈូងតម្រង់ទៅខាងប្រុស បើត្រូវត្រង់ខ្លួនប្រុសណា ពួកស្រីៗ នាំគ្នាទៅទាញអូសយកប្រុសនោះមកទុកក្នុងវង់របស់ខ្លួនឲ្យធ្វើជា ខ្ញុំបំរើ ហើយក៏បោះឈូងនោះទៅឲ្យខាងប្រុសវិញ បើខាងប្រុសចាប់បាន ត្រូវលោះយកគូកនដែលនៅក្នុងវង់ស្រីមកវិញ ហើយបោះឈូងទៅឲ្យស្រី ចេះតែបោលគ្នាទៅវិញទៅមក ៗ ល្បែងនេះ គេសន្មតថាឈ្នះ ដោយអាស្រ័យពួកខាងណាបោលឈូងទៅត្រូវច្រើនជាង គឺបើស្រីចាប់បានបោលទៅប្រុស ត្រូវច្រើនជាង គេឃើញប្រុសៗ មកនៅក្នុងវង់ស្រីជាច្រើន, បើខាងប្រុសឈ្នះគេឃើញមានស្រីជាច្រើនមកនៅក្នុងវង់ប្រុស ៗ ឯអ្នកលេងល្បែងនេះ មានចិត្តរីករាយសប្បាយណាស់ ដោយពួកក្រមុំនឹងកំឡោះបានស្និទ្ធស្នាលនិយាយស្ដីជាមួយគ្នា ឥតកោតញញើតទេ ៗ

## លេងឈូងប្រៀង

ពួកអ្នកលេងចែក ២ ពួក គឺពួកខាងប្រុស ពួកខាងស្រី ដូចលេងឈូងបោលដែរ ប៉ុន្តែបើចាប់ឈូងបានហើយ មិនបោលគ្នាទៅវិញទៅមកទេ គឺបើខាងប្រុសចាប់បាន ត្រូវខាងស្រីរាយទំនុកប្រៀងផ្សេងៗ, បើខាងស្រីចាប់បានវិញ ត្រូវខាងប្រុសប្រៀង, ល្បែងនេះសន្មតថាឈ្នះចាញ់ដោយហេតុ ពួកខាងណាចាប់ឈូងបានច្រើនដងត្រូវឈ្នះ ខាងណាចាប់មិនសូវបានត្រូវចាញ់គេ គេប្រើឲ្យប្រៀងច្រើនជាងគេ ៗ

**ចប់ល្បែងបោលឈូង តែប៉ុណ្ណោះ**

# ល្បែងទាញព្រ័ត្រ

នៅពេលថ្ងៃបរតើត្រង់ ជាថ្ងៃទី ៣ នៃថ្ងៃចូលឆ្នាំ ពួកក្រមុំកំឡោះបបួលគ្នាលេងទាញព្រ័ត្រ នៅក្នុងទីវត្ត ៗ របៀបលេង មានខ្សែពួរ ១ វែងប្រវែង ៥០ ម៉ែត្រ ធ្វើពីជក់ដូងទំហំប៉ុនកដៃ ដាក់លាសន្ធឹងនៅដី, ពួកប្រុសកំឡោះចំនួន ២០ នាក់កាន់ក្ដុយពួរម្ខាង ពួកស្រីក្រមុំចំនួន ២០ នាក់ដែរ កាន់ក្ដុយពួរម្ខាង ហើយក៏តាំងទាញប្រណាំងគ្នាចំប្រឹងទាញពេញទំហឹងទាំងសងខាង ៗ ខាងប្រុសឃើញមួរជើងខោយកសំពត់ក្រម៉ាក្រវាត់គាតនៅចង្កេះយ៉ាងមាំ, ខាងស្រីឃើញចងក្បិនក្រវាត់សំពត់ដូចគ្នា ៗ ក្នុងពេលដែលទាញនោះ ឃើញបែកញើសហូរសស្រាក់តែរៀងខ្លួន ទាំមាត់ទំលាក់ខ្លួនបន្ទាបទននបុះស្ទក់លើខ្សែពួរ ៗ ចំណែកអ្នកកាន់ក្ដុយពួរទាំងសងខាង ឃើញយកក្ដុយរុំព័ទ្ធជុំវិញចង្កេះខ្លួន ហើយបន្ទាបជើងម្ខាង ជើងម្ខាងទៀតដាក់ដីដែងចំប្រឹងមិនឲ្យខ្សែពួររបូតពីចង្កេះខ្លួន ៗ ពួកអ្នកលេងនិងពួកអ្នកឈរមើល ព្រួសូរតែស្រែកទ្រហឹងអឺងកង ចំប្រឹងទាញរោះឃើត ៗ មើលទៅឃើញដូចជាក្អួបរ៉ារនៅផ្លូវ, ប្រហែល ១ ស្របក់ស្រាប់តែព្រួសូរហោរក្រេវឡើង ចួនកាលឃើញខាងប្រុសទាញខ្សែអូសទាំងស្រីមកខាងទីរបស់ខ្លួន ចួនកាលឃើញខាងស្រីទាញអូសប្រុសៗ នាំមកខាងទីរបស់ខ្លួន, អ្នកឈរមើលទាំងប៉ុន្មានក៏សើចក្អាកក្អាយសប្បាយរាល់គ្នា ៗ

ល្បែងនេះ ចួនកាលខាងប្រុសតិចជាងខាងស្រី ដូចជាខាងប្រុស ១០ នាក់ខាងស្រី ១៥ នាក់ ព្រោះធម្មតាមនុស្សប្រុសច្រើនជាអ្នកកម្លាំងខ្លាំង ឯមនុស្សស្រីមានកម្លាំងខ្សោយ អាស្រ័យហេតុនេះហើយ បានជាដល់ពេលលេងទាញព្រ័ត្រម្តងៗ ខាងស្រីច្រើនតែឲ្យបានគ្នាច្រើនជាងខាងប្រុស ។ កាលលេងទៅចួនកាលខាងប្រុសឈ្នះ ចួនកាលខាងស្រីឈ្នះ ។

**ចប់ល្បែងទាញព្រ័ត្រ តែប៉ុណ្ណោះ**

ល្បែងទាំងប៉ុន្មានដែលខ្ញុំបានតែងមកនេះ ខ្ញុំបានដឹងតែល្បែងទាញព្រ័ត្រ១ទេ ដែលជាល្បែងមានជាប់ទាក់ទងនឹងរឿងព្រេង, ឯល្បែងក្រៅពីនេះ ខ្ញុំគ្រាន់តែធ្លាប់លេងធ្លាប់ឃើញអ្នកស្រុកលេងត ៗគ្នា មកជាយូរអង្វែងហើយ ។

ឯរឿងព្រេងទាញព្រ័ត្រនោះ ខ្ញុំបានឮពីសំណាក់ព្រះតេជព្រះគុណព្រះសត ព្រះមហាវិមលធម្ម នាមថោង ចាងហ្វាងសាលាបាលីជាន់ខ្ពស់ កាលគង់ព្រះជន្មនៅឡើយ ។ លោកនិទានថា ល្បែងទាញព្រ័ត្រកើតមានឡើងជាដំបូង គឺមកពីពួកយក្សនឹងពួកទេវតាប្រឡងប្រកួតកម្លាំងគ្នា ដូចមានក្នុងរឿងរាមាយណៈ (រាមកេរ្តិ៍) ។

ដំណាលថា មានថ្ងៃមួយ ពួកយក្សកើតសេចក្តីច្រណែនឫស្យានឹងពួកទេវតា ថាពួកទេវតាគ្មានរិទ្ធិកម្លាំងខ្លាំងពូកែជាងពួកយើងជាយក្សទេ ប៉ុន្តែបានទីឋានខ្ពស់ជាងពួកយើង ដោយសារតែព្រះជាម្ចាស់ (ព្រះឥសូរ)

ទ្រង់ប្រោសប្រាណរាប់អាន ប្រសិនបើពួកទេវតាចង់ល្បងពិសោធន៍ខាងកម្លាំងពលំវិញ មុខជានឹងចាញ់យើងឥឡូវហើយ ។ ពួកទេវតាបានឮក៏មានសេចក្តីអៀនខ្មាសនឹងពួកយក្ស បានអួតតតបទៅនឹងពួកយក្សវិញថា យើងមិនខ្លាចទេ មានត្រឹមកម្លាំងយក្ស ប្រសិនបើចង់ប្រកួតកម្លាំងគ្នាយើងក៏ហ៊ានដែរ វៀរលែងតែប្រើវិធីយុទ្ធសង្គ្រាមចេញ សូមឲ្យប្រើវិធីអ្វីមួយ ចំពោះប្រកួតតែកម្លាំងនឹងកម្លាំង ។ កាលណោះ យក្សនឹងទេវតាបានសុខចិត្តមូលមាត់ព្រមគ្នាថា ត្រូវយកវិធីទាញព្រ័ត្រភ្នាល់កម្លាំងគ្នា បើខាងយក្សទាញឈ្នះទេវតា យក្សត្រូវបានឋានទីខ្ពង់ខ្ពស់ជាង ទោះចូលទៅគាល់ព្រះឥសូរក្តី ឬទៅកាន់ទីប្រជុំឯណានិមួយក្តី ត្រូវយក្សមានសិទ្ធិអង្គុយលើអាសនៈខ្ពស់ជាងទេវតាជាប ហើយក៏ព្រមព្រៀងគ្នាថានឹងយកវិធីទាញព្រ័ត្រជាវិធីប្រកួតកម្លាំងគ្នា ហើយក៏ជំនុំគ្នាយកនាគ ១ មកធ្វើជាព្រ័ត្រទាញក្នុងវេលាថ្ងៃស្អែកមុខនេះ ។ មុនពេលទាញព្រ័ត្រនេះ ខាងពួកទេវតានាំគ្នាដើរស្រចុះស្រឡើងនៅមុខព្រះលានព្រះឥសូរ ទទួលពេលនោះព្រះពាលីក៏ចូលទៅគាល់ព្រះឥសូរដែរ ស្តេចពាលីបានឃើញហេតុដូច្នោះ ក៏ត្រាស់សួរទៅទេវតាថា ចុះមានហេតុកេទដូចម្តេច បានជានាំគ្នាដើរស្រចុះស្រឡើង ៗ ទេវតាបានទូលតាមដំណើរសព្វគ្រប់ដល់ស្តេចក្រុងពាលី ៗ ក៏មានបន្ទូលធានាអះអាងថា នឹងជួយដោះទុក្ខដល់ពពួកទេវតា ប៉ុន្តែឲ្យពួកទេវតាធ្វើតាមបង្គាប់នៅពេលដែលទាញព្រ័ត្រនោះ គឺ

ត្រូវឲ្យពួកទេវតាទាញខាងក្បាលនាគឲ្យពួកយក្សទាញខាងកន្ទុយ លុះដល់ពេលនឹងទាញឲ្យឈរតម្រៀបគ្នា ពីក្បាលនាគទៅទល់នឹងពោះនាគ នៅពេលកំពុងទាញ ឲ្យទេវតា១អង្គយកម្រាមដៃចុចត្រង់ផ្ចិតនាគ តែកាលណាចុចទៅ នាគមុខជារារស៊ើបហើយរានឹងខំប្រឹងរាត់កន្ទុយឲ្យផុតរបូតអំពីដៃយក្ស ផ្សំនឹងកម្លាំងទេវតាផង កម្លាំងនាគផង មុខជានឹងឈ្នះយក្សពុំខាន ។ ពួកទេវតាកាលបើបានស្ដាប់ស្ដេចក្រុងពាលីពន្យល់កលកិច្ចដូច្នោះ ក៏មានចិត្តរីករាយសោមនស្សណាស់ ។ លុះដល់ពេលទាញព្រ័ត្រពួកទេវតាក៏សូមទាញខាងក្បាលនាគ ពួកយក្សក៏យល់ព្រម ដល់ប្រកួតទាញនោះ ពួកទេវតាក៏មានជ័យជំនះឈ្នះពួកយក្សប្រាកដក្នុងពេលនោះមែន ។ ហេតុនេះហើយបានជាមានទំនៀមទម្លាប់ជាប់រហូតមកដល់សព្វថ្ងៃនេះគ្រប់តែស្រុក តែកាលណាចង់ភ្នាល់កម្លាំងគ្នា គេតែងតែលេងល្បែងទាញព្រ័ត្រនេះ ។ ព្រោះហេតុនេះ បានជាគេឃើញរូបចម្លាក់នៅជញ្ជាំងប្រាសាទនគរវត្ត មានរូបនាគ១វែងលៃ ខាងក្បាលឃើញសុទ្ធតែពួកទេវតា ខាងកន្ទុយឃើញសុទ្ធតែពួកយក្សទាញប្រជែងគ្នាមានទំនងដូចជារបៀបដែលយើងទាញព្រ័ត្រដូច្នោះ ប៉ុន្តែខុសគ្នាតែត្រង់ព្រ័ត្រ យើងសព្វថ្ងៃនេះប្រើខ្សែពួរជំនួសព្រ័ត្រ ។ ឯខ្សែពួរនោះធ្វើពីជក់ដូង ឬ ពីផ្ដៅ ប្រើជាព្រ័ត្រសម្រាប់ទាញ ។

**ចប់រឿងព្រេងទាញព្រ័ត្រ តែប៉ុណ្ណោះ**

ម៉ៅ-មុី យោក្បាត់ ក្រសួងមហាផ្ទៃ ភ្នំពេញ

សុភាសិត ភាគទី ២

លោក ពយ-ប៊ុក ក្រមការលេខ ២ រៀបរៀង

ឃុនសុវត្ថិវេទី យូរ-អ៊ុន ពិនិត្យកែ

# ១.– ជាតិវគ្គ

១ – គ្រហស្ថទង់ជ័យ ព្រះសង្ឃវិន័យ ជាសម្បត្តិខ្លួន ទង់ជ័យវិន័យ ត្រូវចាំថែជួន ប្រតិបត្តិតាមក្បួន កុំឆ្វេសសព្វថ្ងៃ ៗ កប៉ាល់នាវា សព្វយាត្រា មានត្រីវិស័យ ដូចមនុស្សក្នុងលោក ត្រូវពឹងទង់ជ័យ ទើបផុតទុក្ខភ័យ ថ្កើងវឌ្ឍិបេស្ដា ៗ ទង់ដូចប្រទីប បំភ្លឺគ្រប់ទ្វីប ចក្រវាឡ ឲ្យសត្វទីពឹង ចំរើនសុខា ក្នុងវដ្ដសង្សារ រៀងដល់និព្វាន ៗ

២ – បុគ្គលណាស្លាប់ព្រោះជាតិ,ធម៌ បុគ្គលនោះឈ្មោះល្អទុកដូចរស់ អ្នកដែលលះបោលជាតិ,ធម៌ស្មោះ បើទុកជារស់ក៏ដូចស្លាប់ ៗ

៣ – អ្នកណាចិត្តហានក្លា ព្រេងវាស្នាបើកទ្វារឲ្យ អ្នកណាចិត្តកំសោយ តែងថ្ងោះថ្ងោយជួបក្ដីក្រ ៗ ប្រៀបដូចមាន់ប្រជល់ មិនចាញ់កល់មាន់សម្ល តែងចូលសង្វៀនត ប្រាំងសត្រូវមិនញញើត ៗ

៤ – វល្លិ៍ស្មៅតូចមែនពិត តែបើរឹតដំរីបាន កណ្ដៀរសត្វតិរច្ឆាន កព្ទូនថ្កានដំបូកធំ ៗ ធៀបដូចសាមគ្គី កើតពេញទីក្នុងសង្គម ជាគុណគាប់ឧត្តម អាចកើតសម្រិទ្ធិជោគ ៗ

៥ – បើធ្វើកិច្ចការ បូវគិតពិចារ ឲ្យបានម៉ាំមួន បើបរាជ័យ ចាញ់ដៃប៉ោះខ្លួន ត្រូវខំថែធួន សួនទ្វេឡើងទៀត ។ បើដើរមគ្គា ភ្លាត់ជួល ផ្កាប់ផ្ញា ត្រូវក្រោកខ្ទឹឃ្លាត ប្រឹងដើរតទៅ លុះដល់ជាអាទិ៍ ទីដែលសង្ខាត ទើបសម្រេចផល ។

៦ – គួរខ្លាចក៏ខ្លាច បើហ៊ានប៉ុកាច ប្រើសុភាពពិត អ្នកហ៊ានស្បែកដាច អ្នកខ្លាចស្បែកស្វិត នេះសុភាសិត បណ្ឌិតប្រដៅ ។

៧ – ស្រមោចរូបមាឌតូចមែនពិត តែសាមគ្គីចិត្តសម្លាប់បាន មេអំបៅដង្កូវធំរូបប្រាណ ជនកល្យាណគួរយកតម្រាប់តាម ។

៨ – បូរបាខំរៀន សិល្បសាស្ត្ររបៀន កុំបាប្រមាទ ត្រូវខំទន្ទេញក្បួនច្បាប់ឱភាំទ ធម៌អាចិបទបាប ទាន់វ័យនៅក្មេង ។ ជាតិជាប្រុសស្រី នៅនាលោកិយ អប់រំខ្លួនឯង ដោយសិល្បវិជ្ជា ម៉ឺងម៉ាត់ ជាក់ស្តែង គុណវិជ្ជាតែង ឲ្យរុងរឿងក្រៃ ។

៩ – រកបាវជូនមែន រកភរិយាសែន ព្រួយហើយជូនផង ការរពាផែនដី ជូនក្រែកគ្នូង ពលោកជាតុហោង ជូនកត្តគណនា ។

(ខ) លីបាវប្ញណើជូនណាស់សា តែជូនភរិយាក្រៃបំផុត ការព ផែនដីជាតិសាសន៍សុខ ជូនផុតលើសលែងជូននានា ។

១០ – ត្រូវនឹកប្រមូលការគ្រប់មុខ មកពិនិត្យទុកមុននឹងធ្វើ ការណាយល់ថាគាប់ប្រសើរ ត្រូវប្រឹព្យាយាមនឹងមានៈ ។ ព្រោះធម៌ពីរ

នេះជាអាវុធ សម្រាប់តយុទ្ធបសត្រូវ គ្រោះកាចស្អុនការដែលកសួះ ឲ្យចាញ់គេដះការសម្រេច ៗ

១១ – អ្នកណាខ្សោយ ព្យាយាមកាប់ឆ្កា មែកឈើពល់ថ្ងៃ លុះអនាគត ឲ្យកុំសង្ស័យ កើតផ្លូវប្រស័យ ក្នុងព្រៃព្រឹក្សា ៗ

១២ – ប្រទេសមួយស្តេចពីរមិនកើតឡើ វត្តមិនខ្ពង់គួមសំយកដពីរ ព្រះពុទ្ធទ្វេអង្គហោចសាមគ្គី អាទិត្យពីរទីក្តៅនៅមិនបាន ៗ

១៣ – បើចង់ត្រឹងតាំងយកឈ្នះចាញ់ បើចង់អញ្ញាឲ្យដល់កាល បើរៀនវិជ្ជាឲ្យផុតពាល ទើបអាចបណ្តាលឲ្យគុណគាប់ ៗ

១៤ – អ្នកទឹកមិនស្គាល់ទន្លេស្ទឹង មិនស្គាល់ថ្កបឹងកុកក្រសារ ពានរមិនស្គាល់ព្រៃព្រឹក្សា អ្នកកាន់សាសនាមិនស្គាល់ព្រះ ៗ

១៥ – លំបាកខ្លួនប្រាណទើបស្គាល់ធម៌ លំបាកខគរទើបសុរិឡ័យ ធ្វើវដ្តសង្សារលំបាកក្រៃ គប់ពាលចង្រៃលំបាកលើស ៗ

១៦ – ស៊ូធ្វើសង្គ្រាមទើបនាមជាតិល្បី ស៊ូចុះចាញ់ស្រីទើបក្តីស្ងប់ស្ងាត់ ស៊ូប្រឹងធ្វើការទើបស្ងាពរអ័ត្ត ស៊ូប្រតិបត្តិទើបខ្ជាត់មន្ទិល ៗ

(ស៊ូប្រឹងធ្វើការទើបស្ងាពរអ័ត្ត ស៊ូប្រតិបត្តិទើបខ្ជាត់មន្ទិល) ៗ

ស៊ូក្នុងការរៀនទើបរៀនចេះចប់ ស៊ូកុំឲ្យស្អប់ទើបអប់សុរិល

ស៊ូធ្វើល្អគាត់ទើបបាត់ខ្ជួចចិល ស៊ូទំកាន់សីលទើបក្របិលបាបបាន)

(មានត)

# ប្រវត្តិសាស្ត្រសង្ខេបប្រទេសឥណ្ឌា

(១)

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម រៀបរៀង

(តមក)

---

លុះតមកក្នុងរវាងព្រះពុទ្ធសករាជ ៩៩៣ ត្រូវពួកហ៊ុនលុកលុយដណ្ដើមយកផែនដីនៅខាងអីពិនទៅ ហើយតមកទៀត ២៥ ឆ្នាំក៏ត្រូវសត្រូវដណ្ដើមយកផែនកស្មីរៈទៅទៀត ហេតុដូច្នេះ តាំងអំពីពុទ្ធសករាជកន្លងមកជាង ១ ពាន់ឆ្នាំ អំណាចរបស់រាជវង្សយូអេជីក៏មាននៅត្រឹមខែត្រដែនគន្ធារៈប៉ុណ្ណោះ ។

កាលអំណាចរបស់រាជវង្សយូអេជីសាប់សូន្យថយខ្សោយចុះទៅ អាណាចក្រនៅខាងដិកក័នត្រឡប់ជាមានសេចក្ដីចំរើនរុងរឿងឡើងដល់ ២ អាណាចក្រ គឺអាណាចក្រអន្ធរៈ និងសុរាស្ត្រ ។ ទីទួលខ្ពស់ដែលជាផែនដីរបស់ដិកក័នសុទ្ធនោះ គឺនៅជាបន្លោះទន្លេគោធាវរីនិងទន្លេក្រិស្នា មានអាណាចក្រមួយតាំងខ្លួនឡើងបាន កាលពីពុទ្ធសករាជ ៣២៣ ហៅថាអន្ធរៈ អំពីដើមមកផែនដីចំណែកនេះធ្លាប់នៅជាចំណុះអាណាចក្រមគធៈ ដោយហេតុព្រះបាទពិន្ទុសាររាយយកបាន កាលពីពុទ្ធសករាជ ២៦៣ ដែលគួរនាំឲ្យសន្និដ្ឋានថាជាគ្រាដំបូង ដែលពួកអរិយកៈបានលុកលុយចូលទៅក្នុងផែនដីដិកក័ន ។ ព្រះរាជឱរសរបស់ព្រះបាទពិន្ទុសារ គឺព្រះបាទអសោកមហារាជ ទ្រង់បានព្យាយាមផ្សាយព្រះពុទ្ធសាសនាចូល

មកក្នុងដែនដីនេះទាល់តែបាន ។ កាលព្រះបាទអសោកមហារាជទិវង្គត់ ហើយ សីសុកៈ ដែលព្រះបាទអសោកមហារាជ ទ្រង់តាំងឲ្យជាអ្នកស្ដីការរាជការនៅដែននេះ ក៏មិនព្រមចំណុះដែនមគធៈតទៅទៀតហើយ ប្រកាសតាំងជាឯករាជ្យឡើងតាំងជាអាណាចក្រអន្ធ្រៈនេះឡើង កាលពុទ្ធសករាជ ៣៤៣ មានអាណាខែត្រតាំងអំពីកុរិន្ទិយៈនៅទិសខាងជើង រហូតចុះមកដល់ទន្លេក្រិស្នានៅទិសខាងត្បូង, ដំបូងតាំងទីក្រុងនៅស្រុកអមរវតី លើច្នេរទន្លេក្រិស្នាខាងក្រោម លុះកាលតមក ទើបផ្លាស់មកតាំងនៅស្រុក ប្រតិឋនៈបុរៃឋនៈ លើច្នេរទន្លេគោធាវរីខាងលើ ។ ឯវង្សក្សត្រដែលគ្រប់គ្រងនៅស្រុកនេះហៅថា វង្សសាតាការនិស បានគ្រប់គ្រងនៅដែននេះជាវេលា ៤៥៦ ឆ្នាំ គឺតាំងអំពីពុទ្ធសករាជ ៣៤៣ រហូតដល់ពុទ្ធសករាជ ៧៧៨ នៅវេលាដែលក្សត្រពងវង្សនេះគ្រប់គ្រងនោះ ការផ្សាយព្រះពុទ្ធសាសនាៈនៅក្នុងដែនដកកន ដែលព្រះបាទអ-សោកបានចាត់ផ្សាយមកហើយនោះ ក៏បានធ្វើតទៅទៀតដោយប្រពៃ ទើបប្រទេសនេះមានព្រះស្តូបនិងអនុស្សាវរីយ៍ដេរដាសពាសពេញ ។ នៅក្នុងសម័យនេះហើយដែលព្រះពុទ្ធសាសនាបានមកប្រតិស្ឋាននៅនាសិក, សញ្ចីនិងអមរវតី ។ ទុកជាមានព្រះពុទ្ធសាសនាចំរើនដូច្នេះហើយក៏ដោយ ក៏នៅតែមានក្សត្រអង្គខ្លះក្នុងរាជវង្សសាតាការនិសគោរព

រាប់អានសាសនាព្រាហ្មណ៍ក៏មាន មានអ្នកខ្លះ កាន់សាសនាព្រាហ្មណ៍ផង ពុទ្ធសាសនាផង ប្រព្រឹត្តទៅតាមព្រះរាជនិយមក៏មាន ។

ព្រះចៅផែនដីអន្ទរៈទាំងឡាយនេះ មានគូប្រណាំងប្រជែងដែលសំខាន់គឺព្រះចៅផែនដីសុរាស្ត្រ ដែលជាពូជអម្បូររបស់ពួកដែលត្រូវពួកយូអេជីបណ្តេញចេញមកពីខែត្រដែនសេអីស្តាននឹងខែត្រសិន្ធុ ក្នុងរវាងពុទ្ធសករាជ ៥០០ ទើបថយចុះទៅខាងឈូងសមុទ្រ កាធីវរ និងខាងទីទំនាប គុជរដ្ឋ ដែលក្នុងសម័យបូរាណហៅថា សុរាស្ត្រ ។ នៅតំបន់នេះមានកំពង់ជំនួញហៅថា មារីកាសា (វេលានេះហៅថាម៉ារេជ) ដែលជាកំពង់សំខាន់មួយខាងផ្លូវជំនួញរបស់ក្រិក ។ មួយវិញទៀត ពួកនេះធ្លាប់នៅក្នុងស្រុកចំណុះរបស់ក្រិកខាងអ៊ីរ៉ានមកជាវេលាយូរ ទើបបានទទួលអារ្យធម៌របស់ក្រិកមកជាច្រើន ហេតុដូច្នេះ កាលបានតាំងឡាក់ឋានខាងសុរាស្ត្រហើយ ក៏ធ្វើឲ្យផ្លូវជំនួញរវាងឥណ្ឌានឹងក្រិក, រោមចំរើនឡើង ៗ លុះតមកក្នុងរវាងពុទ្ធសករាជ ៦០០ ឆ្នាំ ទើបមានសង្គ្រាមរវាងដែនសុរាស្ត្រ នឹងដែនអន្ទរៈជាច្រើនដងច្រើនគ្រា ។ ដើមហេតុនេះ សឹកសង្គ្រាមនេះ មកអំពីសាសនាច្រើនជាងរឿងដទៃទៀត តែក្នុងរវាងដែលធ្វើសង្គ្រាមនោះមិនមានរឿងរ៉ាវជាពិតប្រាកដថា តើខាងណាជាពួកពុទ្ធសាសនា ខាងណាជាពួកសាសនាព្រាហ្មណ៍ ។

សង្គ្រាមគ្រានោះ ជាន់ដើមបែកខាងអន្ធ្រៈមានរបៀប ៗ ក្នុងពុទ្ធសករាជ ៦៦៩ ព្រះបាទគោតមីបុត្រ ក្សត្រប្រទេសអន្ធ្រៈ ធ្វើគត់ព្រះបាទនហាបនៈ ក្សត្រសុរាស្ត្រចេញបាន ទើបទ្រង់បានដែនដីសុរាស្ត្រមកទុកក្នុងការគ្រប់គ្រងរបស់ព្រះអង្គ តែព្រះអង្គទ្រង់តាំងព្រះអង្គម្ចាស់ ១ អង្គនៅសុរាស្ត្រនោះឯងជាអ្នកគ្រប់គ្រងតរៀង ៗ មក លុះដល់ពុទ្ធសករាជ ៦៨៨ មានក្សត្រគ្រងនគរសុរាស្ត្រ ១ អង្គតាំងក្បត់ឡើងហើយបានច្បាំងឈ្នះមហាក្សត្រអន្ធ្រៈ បានដែនដីមកបញ្ចូលថែមទៀតជាច្រើន ៗ តាំងអំពីនោះមក អាណាចក្រអន្ធ្រៈក៏មានព្រំប្រទល់ដែនដល់ដីកកន់ ហើយគង់ទ្រង់រហូតមកដល់ពុទ្ធសករាជ ៧៧៨ ទើបត្រូវជន ១ ពួកហៅថាបល្លវៈ ទំលាយបំផ្លាញ ៗ ឯពួកបល្លវៈនេះមិនទាន់មានគេដឹងឫសគល់ពិតប្រាកដទេ តែសន្និដ្ឋានថាជាពួកប៉ារថែយ៍ ដែលបានដើរកាត់ស្រុកអ៊ីរ៉ានចូលមកក្នុងឥណ្ឌា កាលពីរវាងពុទ្ធសករាជ ៣០០ ៗ ចំណែកខាងពួកស្តេចគ្រងនគរដែលតាំងខ្លួនឡើងបាន កាលពីពុទ្ធសករាជ ៦៨៨ នោះក៏តាំងឡាក់ហាន ហើយមានអំណាចក្នុងដែនសុរាស្ត្រ ហើយលុកចូលមករហូតដល់ដែនសិន្ធុនិងមាលវៈ វង្សក្សត្រដែលគ្រប់គ្រងនៅខេត្តដែននេះបានគ្រប់គ្រងដែននេះរហូតដល់ពុទ្ធសករាជ ៨៥៣ ទើបត្រូវវង្សក្សត្រគុប្តៈផ្តួលរំលំទៅ ៗ

តាំងអំពីព្រះបាទអសោកសោយទិវង្គតទៅហើយរហូតមកដល់ពុទ្ធ-សករាជ ៨០០ ឆ្នាំ ដែនដីនៅខាងទន្លេគង្គា ដែលធ្លាប់ជាទីប្រជុំនៃអារ្យៈធម៌របស់ឥណ្ឌាមកអំពីដើមនោះ ក៏ទ្រុឌទ្រោមសាបសូន្យទៅជាច្រើនមិនមានអំណាចឬកេរ្តិ៍ឈ្មោះយ៉ាងណាឡើយ លុះមកដល់ព្រះពុទ្ធសករាជ ៨៣៣ ទើបត្រឡប់តាំងខ្លួនមាន កេរ្តិ៍ឈ្មោះល្បីល្បាញឡើងវិញ ដោយមានព្រះអង្គម្ចាស់ជាវង្សក្សត្រគប់គ្រងក្រុងរាជគ្រឹះមកអំពីដើម ១ អង្គ ទ្រង់ព្រះនាមស្រីគុប្តៈ បានតាំងខ្លួនឡើងហើយលុបលាងអំណាចក្សត្រវង្សយូអេជីអស់ទៅ លុះតមកដល់ពុទ្ធសករាជ ៨៥១ ទើបព្រះរាជនត្តារបស់ព្រះបាទស្រីគុប្តៈព្រះនាមថា ព្រះបាទចន្ទ្រគុប្តៈទី ១ ទ្រង់មានអំណាចពេញគ្រប់គ្រងខេត្តដែនបេង្គាល់, រាជគ្រឹះនិងកោសល ហើយទ្រង់តាំងទីក្រុងនៅស្រុកបាដលីបុត្រ ។ ព្រះរាជឱរសរបស់ព្រះបាទចន្ទ្រគុប្តៈទី ១ ទ្រង់ព្រះនាមព្រះបាទសមុទ្រគុប្តៈទ្រង់មានរិទ្ធិខ្លាំងពូកែ ទ្រង់លើកកងទ័ពទៅច្បាំងខាងខេត្តដែនជិតគ្នា ៗ ក្សត្រតមក ១ អង្គទៀត ទ្រង់ព្រះនាម ចន្ទ្រគុប្តៈទី ២ ទ្រង់វាយបានដែនមាលវៈ, គុជរដ្ឋនិងសិន្ធុ ។ ហេតុដូច្នោះ មកដល់រាងពុទ្ធសករាជ ៩៥៣ អាណាខេត្តរបស់រាជវង្សគុប្តៈបានរីកធំឡើង តាំងអំពីទន្លេសិន្ធុរហូតដល់ទន្លេព្រហ្មបុត្រ និងអំពីភ្នំហិមាលយារហូតដល់ទន្លេគោធាវរី ដែនមគធៈក៏ត្រឡប់បានសេចក្តីរុងរឿងឡើងវិញម្តងទៀត ។

រាជវង្សគុប្តៈនេះបានផ្លាស់ទីក្រុងជាច្រើនគ្រា ជាន់ដំបូងផ្ទេរតាំងទីក្រុងនៅបាដលីបុត្រ តមកបានមកតាំងទីក្រុងនៅរាជគ្រឹះ តមកទៀតទៅតាំងនៅស្រុកកោសម្ពី ។ ស្រុកកោសម្ពីនេះជាកន្លែងសមគួរនឹងតាំងទីក្រុង គឺតំបន់ជាទីប្រជុំ កណ្តាលរវាងដែនសិន្ធុនឹងបេង្គាល់ហើយជាសម្រាប់ត្រួតត្រាទៅត្រដែនមាលវៈនឹងដឹកកន់បានដោយងាយស្រួលផង ។ តែរាជវង្សនេះនៅតែមិនទាន់ពេញព្រះទ័យ ទើបផ្លាស់ទៅនៅក្រុងពារាណសី, ឧជ្ជេនី, បេតិយនឹងសញ្ចី ។ ឯរាជវង្សគុប្តៈនេះបានចំរើនរុងរឿងបំផុតក្នុងសម័យព្រះបាទកុមារគុប្តៈ (រវាង ព. ស. ៩៩០) លុះមកដល់ ព. ស. ១០២០ក៏ទ្រុឌទ្រោមថយថ្វីអំណាចដោយហេតុពួកហ៊ុនលុកលុយចូល ។

ឯឋានៈរបស់ព្រះពុទ្ធសាសនាក្នុងសម័យរាជវង្សគុប្តនោះ យើងបានដឹងរឿងពិតប្រាកដ ដោយអាស្រ័យសេចក្តីរាយការកត់ហេតុរបស់លោកសង្ឃចិន ១ អង្គឈ្មោះ ហ្វាហៀន ដែលបានចូលមកតណ្ឌៀកាលពីពុទ្ធសករាជ ៩៤២ ដោយតាំងចិត្តស្វះស្វែងរកគម្ពីរព្រះពុទ្ធសាសនា សេចក្តីកត់ហេតុរបស់លោកនេះនាំឲ្យយើងបានដឹងថា ព្រះពុទ្ធសាសនាក្តី ស្រុកទេសដែលកាន់ព្រះពុទ្ធសាសនាហើយធ្លាប់ចំរើនរុងរឿងកាលពីសម័យពុទ្ធកាលក្តី បានទ្រុឌទ្រោមសាបសូន្យទៅជាច្រើន ក្នុងរយៈវេលាជាង ៩០០ ឆ្នាំក្រោយព្រះពុទ្ធបរិនិព្វានមក ។ លោកហ្វាហៀននោះគេបានទទួលរាប់រងយ៉ាងរុងរឿងក្នុងតណ្ឌៀ ព្រះបាទចន្ទ្រគុប្តៈទី ២

កំពុងគ្រប់គ្រងក្នុងវេលានោះ បានបាត់ឲ្យលោកបានទៅមើលស្ថានទីផ្សេង ៗ ដែលទាក់ទងនឹងពុទ្ធប្រវត្តិ ។ ក្នុងសេចក្ដីរាយការបស់លោកនិយាយថា ស្រុកទេសផ្សេង ៗ ដែលចំរើនរុងរឿងក្នុងសម័យពុទ្ធកាលត្រូវទំលាយវិនាសអស់ជាច្រើន ក្នុងសាវត្ថីស្ទើរតែទៅជាព្រៃអស់ ក្រុងកបិលពស្ដុក៏កាន់តែដុនដាបណាស់ទៅទៀត ស្រុកកុសិនារា ជាទីដែលព្រះពុទ្ធជាម្ចាស់បរិនិព្វាននោះក៏នៅមានសល់ភិក្ខុត្រឹម ២-៣អង្គ ។ ឯក្រុងបាដលីបុត្រ ដែលលោក ហ្វាហៀន បានឃើញកាលទៅទីក្រុង ដែលសេសសល់ពីបាក់បែក របស់ដែលសំខាន់គឺប្រាសាទរបស់ព្រះបាទអសោក ។ កាលលោកហ្វាហៀន ចេញអំពីក្រុងបាដលីបុត្រហើយ ទើបទៅមើលក្រុងរាជគ្រឹះហើយទៅដល់គយា ដែលជាទីមានព្រៃព្រឹក្សាដុះពាសពេញដូចគ្នាដែរ តែដើមមហាពោធិព្រឹក្សដែលព្រះអង្គបានត្រាស់ដឹងនោះនៅគង់ទ្រង់លូតលាស់ល្អ លោកហ្វាហៀន បានត្រេចទៅក្នុងឥណ្ឌាជាវេលា ១៤ ឆ្នាំ ហើយចុះទូកទៅកោះលង្កា ត្រឡប់មកស្រុកចិនវិញ ក្នុងពុទ្ធសករាជ ៩៥៦ ។

តាមសេចក្ដីរាយការរបស់លោក ហ្វាហៀន ឃើញច្បាស់ថា ព្រះពុទ្ធសាសនាមិនមែនជាសាសនាសម្រាប់ស្រុកក្នុងរាជវង្សគុប្តៈនោះទេ តែមានអនុស្សាវរីយ៍ជាច្រើនសឲ្យឃើញថា ព្រះពុទ្ធសាសនាមានសេចក្ដីសំខាន់ច្រើនដែរ ទុកជារាជវង្សគុប្តៈមិនបានទំនុកបំរុង ក៏មិនបានរំលាយ

បំផ្លាញទេ លុះតមកដល់រាជវង្សគុប្តៈហើយ ទើបពួកពុទ្ធសាសនិកជនត្រូវពួកហ៊ុនប្រើអំណាចបៀតបៀនជាខ្លាំង ៗ

ហ៊ុនចំពួកនេះហៅថា ហ៊ុនស ជាពួកមានពូជខ្សែស្រឡាយជាតិទួគី ៗ ជាន់ដំបូង បានតាំងទីលំនៅ ក្នុងដែនដីសកដៀននឹងបាក់ត្រៀនដែលពួកយូអេជីធ្លាប់នៅមកមុន កាលបានតាំងឡកហានមាំមួនក្នុងដែនដីទាំងពីរនេះហើយ ក៏ខំពង្រីកអាណាខេត្រចេញទៅ រហូតដល់ដែនដីដែលរាជវង្សគុប្តៈគ្រប់គ្រង ។ ក្នុងរវាងពុទ្ធសករាជ ១០០៥ បាននាំគ្នាដើរកាត់ភ្នំហិណ្ឌូកូជ ឆ្លងហួសចូលមកក្នុងដែនបញ្ចាប ។ សម័យនោះរាជវង្សគុប្តៈមានព្រះរាជាធិរាជព្រះនាម សកន្ទគុប្តៈ ព្រះមហាក្សត្រអង្គនេះ ទ្រង់ច្បាំងបណ្តេញឲ្យពួកហ៊ុនចេញទៅបានមួងហើយ លុះដល់ផុតរាជ្យព្រះបាទសកន្ទគុប្តៈហើយ ពួកហ៊ុនក៏ត្រឡប់ចូលមកលុកលុយទៀត ៗ ហើយមិនព្រមថយចេញពីខេត្របញ្ចាបឡើយ ។ ឯនាយករបស់ពួកហ៊ុននេះហៅថា តូរ៉ាម៉ន បាននាំបក្ខពួកលុកលុយចូលទៅរហូតដល់ដែនម៉ាលវៈ ហើយដល់មកក្នុងពុទ្ធសករាជ ១០៣៨ បានដណ្តើមយករាជសម្បត្តិរបស់ព្រះមហាក្សត្ររាជវង្សគុប្តៈ ព្រះនាមពាណពិត្យៈទៅបាន ។

# ស័ព្ទបារាំងប្រែជាខ្មែរ

របស់

គណៈកម្មការវប្បធម៌

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម រៀបរៀង

(តមក)

---

Chapitre = វគ្គ

Capitale = ក្រុងធំ, រាជធានី

Langue officielle = ភាសាដែលប្រើជាផ្លូវការ

La loi est l'expression de la volonté nationale = ច្បាប់ជាសេចក្តីសំដែងឆន្ទៈរបស់ប្រជាជាតិ

La liberté = សេរីភាព

Décision motivée = ដីកាសំដែងហេតុផល

Ressource = ធនធាន

Message = ព្រះរាជសារ, សារលិខិត

Grades civils = បណ្តាស័ក្តិ

Immunité = អភ័យឯកសិទ្ធិ

Janvier = មករា

Février = កុម្ភៈ

Mars = មីនា

Avril = មេសា

Mai = ឧសភា

Juin = មិថុនា

Juillet = កក្កដា

Août = សីហា

Septembre = កញ្ញា

Octobre = តុលា

Novembre = វិច្ឆិកា

Décembre = ធ្នូ

Conseil du Royaume = ក្រុមប្រឹក្សាព្រះរាជាណាចក្រ

Conseil d'état = ក្រុមប្រឹក្សានៃរដ្ឋ

Conseil de la Famille Royale = ក្រុមសង្គហៈព្រះរាជវង្សានុវង្ស

Conseil de la magistrature = ក្រុមប្រឹក្សាតុលាការ

Haute Cour de Justice = សភាតុលាការជាន់ខ្ពស់

Elire = ជ្រើសតាំង

Nommer = តែងតាំង

Désigner = ចាត់តាំង

Ministére = ក្រសួងរដ្ឋមន្ត្រី

ពាក្យខាងលើនេះ គណៈកម្មការបានប្រែនៅថ្ងៃព្រហស្បតិ៍ ២-១-៤៧.

Secrétariat d'Etat = រដ្ឋលេខាធិការដ្ឋាន

Service = ក្រុម

Directeur de Service = នាយក្រុម

Chef de Serdice = នាយក្រុម

Chef de Cabinet = នាយកាប៊ីណេត

Chef de Bureaux = នាយប៊ុយរ៉ូ

Directeur des Bureaux = នាយកប៊ុយរ៉ូ

Directeur de Cabinet = នាយកកាប៊ីណេត

Chef de Section = នាយផ្នែក

Statut = លក្ខន្តិកៈ

Vertu = គុណធម៌

Sur la proposition de = ដោយសេចក្ដីណែនាំ

(គណៈកម្មការបានប្រែនៅថ្ងៃច័ន្ទ ៦-១-៤៧)

Charte = បទបញ្ញត្តិ ធម្មនុញ្ញ

O. N. U. = អង្គការសហប្រជាជាតិ

Commissaire du Gouvernement = ស្នងរាជការ

Traité = សន្ធិសញ្ញា

Convention = អនុសញ្ញា

Accord = កិច្ចព្រមព្រៀង

Arrangement = សេចក្ដីព្រមព្រៀង

Pacte = កតិកាសញ្ញា

Protocole = ពិធីការ, ពិធីសារ

Pseudonyme = រហ័ស្សនាម

(២៤-១-៤៧

Homonyme = សទិសនាម

Synonyme = វេវចននាម

Vacance = វិស្សមកាល

Journal Quotidien = កាសែតកយថ្ងៃ

Journal hebdomadaire = កាសែតកយសប្ដាហ:

Périodique = កាលិកប័ត្រ

Théorie = ទ្រឹស្ដី

Pratique = វិធីប្រតិបត្តិ

En principe = តាមគោលការ

Paronyme = ត្ល្យទិសនាម

(៣-២-៤៧)

Matériellement = ដោយផ្លូវកាយ

Intellectuellement = ដោយផ្លូវប្រាជ្ញា

Spirituellement = ដោយផ្លូវចិត្ត

Moralement = ដោយសីលធម៌

Volonté = ឆន្ទៈ

Donner procuration = ប្រគល់អាសា

Volontairement = ដោយស្ម័គ្រចិត្ត,ដោយចេតនា

A la lettre = តាមព្យញ្ជនៈ

Dans l'esprit = តាមចេតនារម្មណ៍, តាមអត្ថ, តាមបំណង

Orthographe des mots = អក្ខរាវិរុទ្ធនៃពាក្យ

Donner le mandat = ឲ្យអាណត្តិ

(១៧-៤-៤៧

S-us-entendu = សន្និដ្ឋានវចនៈ

Présidence du Conseil des ministres = ទីស្តីការនាយករដ្ឋមន្ត្រី

Demander des conseils = សុំសេចក្តីប្រឹក្សា

Donner des conseils = ឲ្យសេចក្តីយល់

Explicitement = ដោយនិប្បរិយាយ

Implicitement = ដោយបរិយាយ

Démagogie = ប្រជាភិថុតិ(ការបះញ្ឈារាស្ត្រ

Douane = គយ

Régie = រដ្ឋាការ ឬអាការ

(២៤-២-៤៧)

Geste = អាកប្បកិរិយា

Fanatiste = អធិមុត្តិក

Fanatisme = អធិមុត្តិ

Moyen = ដោយផ្លូវឧបាយ,មធ្យោបាយ

Comportement = អាចារៈ

Tempérament = ចរិត, និស្ស័យ

Caractère = ចរិត,-

Programme = កម្មវិធី, គ្រោងការ

Tourisme = ទេសចរ

Gouvernement de Sa Majesté = ព្រះរាជរដ្ឋាភិបាល

Caractère gai = ចរិតរីករាយ

Caractère politique = មានលក្ខណៈជានយោបាយ

Martyr = ទុក្ករបុគ្គល

Martyriser = ស៊ូស្លាប់

(៣-៣-៦៧)

Sentiment = មនោសញ្ចេតនា·

Etat associé = សមាគមរដ្ឋ

Conférence = ជំនុំការ, សន្និសិទ

Sensation = វេទនារម្មណ៍

Décision = សម្រេច

Guérilla = ទ័ពព្រៃ

Egoïsme = អត្តទត្ថភាព

Altruisme បរទត្ថភាព

Microbe = សុខុមប្រាណ

Miçroscope = សុខុមទស្សន៍

(១០-៣-៦៧)

Matériel = សម្ភារៈ

Prestige = កិត្យានុភាព

Dynamisme = ពលភាព, ថាមភាព

(មានត)

# រឿងសាមកុក

លោកឧកញ៉ា នូវ-កន រៀបរៀង

(តមក)

---

ទើបតាំងតុឲ្យអញ្ជើញហាន់ជូហៀបឡើងគង់លើរតនបល្ល័ង្ក ក្រោមព្រះមហាស្វេតច្ឆ័ត្រ ជួបជុំរាជបរិសទ្យសេវកាមាត្យមុខមន្ត្រីសេដ្ឋីគហបតីរាជបរិវារ សឹងតែក្រាបថ្វាយបង្គំរាល់គ្នា។ ឡារិកគឹកកងក្នុងទីព្រះរាជពេងរម្យ ស្រេចហើយឲ្យយកហាន់ជូពៀននឹងព្រះនាងហោហៅជាមាតា ព្រមទាំងនាងស្នំក្រមការហាន់ជូពៀន ទៅបង្ខាំងទុកក្នុងទីព្រះតំណាក់ចាក់សោមិនឲ្យចេញទៅណាបាន ហាមប្រាមពួកនាហ្មឺនខ្ញុំរាជការមិនឲ្យនរណាទៅមកសួរនាំសោះ វេលានោះនាហ្មឺនមុខមន្ត្រីនូវអស់អាណាប្រជានុរាស្ត្រទាសករបណ្ដាដែលមានទាំងប៉ុន្មាន សឹងមានសេចក្ដីសៅសោកអាណិតអាណាតនៃហាន់ជូពៀននឹងព្រះនាងហោហៅពន់ពេកណាស់ កាលដែលតាំងតុ តាំងហាន់ជូហៀបឲ្យឡើងសោយរាជសម្បត្តិនោះព្រះជន្មវស្សាបាន ៩ ឆ្នាំគត់ (ព. ស. ៧៣៣) ថ្វាយព្រះនាមហៅថាព្រះហៅហៀនតេ ។

ចំណែកតាំងតុក៏តាំងខ្លួនជា "សាំងកុក" ភាសាខ្មែរហៅថាស្ដេចមហាឧបរាជអាចគាន់ព្រះសែងគ្រប់ចូលគាល់រាល់វេលាបានតាមចិត្តប្រាថ្នា នឹងចេញចូលបានដរាប ឯអាជ្ញាសិទ្ធិរិទ្ធានុភាពនៃតាំងតុនោះក៏កាន់តែ

ក៏រឹតក្លាហានមានទៀតជាងពីដើម បណ្ដាសេនាទាហាននឹងបក្ខពួកទាំងប៉ុន្មាន ក៏សឹងតែធ្វើការអាក្រក់ដើរឆក់ដណ្ដើមទ្រព្យរបស់អស់អាណាប្រជានុរាស្ត្របានសេចក្ដីក្ដៅក្រហាយណាស់ ។

ឯចោរនោះក៏បានចូលទៅធ្វើខ្លួន ឲ្យតាំងតុះប្រើប្រាស់ក្នុងកិច្ចរាជការ លីយូជាទីប្រឹក្សាក៏បាននិយាយនឹងតាំងតុះថា សព្វថ្ងៃនេះរាជការផែនដីទាំងមូលក៏ចូលមកនៅក្នុងកណ្ដាប់ដៃនៃលោកទាំងអស់ហើយ សុំកុំឲ្យលោកសំដែងអំណាចឲ្យនាហ្មឺននឹងរាស្ត្របានសេចក្ដីស្អប់ខ្ញាញ់ ចូរលោកធ្យាយបន្ទន់ចិត្តអាណិតស្រឡាញ់អាណាប្រជានុរាស្ត្រ ឲ្យបាននៅជាសុខក្សេមក្សាន្ត លោកក៏នឹងបានចំរើនទូវឥស្សរិយយសក្ខុសធំឡើងទៀត ។ ប្រការមួយទៀតមានមនុស្សម្នាក់នៅខែត្រក្រៅឈ្មោះ សួយ៉ុង មានសតិបញ្ញាល្អណាស់ សុំឲ្យលោកយកខ្លួនសួយ៉ុងនោះមកទំនុកបំរុងតាំងឲ្យមានយសសក្ដិជានាហ្មឺនក្នុងក្រុង លោកក៏នឹងមានកម្លាំងធ្វើការរាជការចំរើនឡើងទៀត តាំងតុះយល់ព្រមក៏ប្រើបំរើឲ្យទៅហៅសួយ៉ុងៗធ្វើព្រងើយកន្តើយមិនបានចូលមក តាំងតុះក៏ចាត់បំរើឲ្យទៅហៅម្ដងទៀត ហើយឲ្យប្រាប់ថាបើសួយ៉ុងរឹងទទឹងមិនចូលមកទេ នឹងឲ្យទាហានទៅចាប់សម្លាប់ចេញឲ្យអស់ទាំងគោត្រ ។ សួយ៉ុងបារម្ភខ្លាចមិនអាចនឹងនៅបាន ក៏រៀបខ្លួនប្រាណចូលមកដល់តាំងតុះៗ ក៏តាំងសួយ៉ុងបានឡើងទីជាមន្ត្រីមានយសស័ក្ដិ តាំងតុះទុកចិត្តជឿយកជាទីប្រឹក្សាការរាជការទាំងពួង ។

ឯហង់ជូពៀនទទឹង ព្រះនាងហោហៅខ្មៅភ្លូក ព្រះស្នំដែលតាំងតុឲ្យឃុំខ្លួនទុកនោះ គឺមានសេចក្តីវេទនាសោកាបានខ្វះនោះស្គាំងស្គមទ្រមដោយទុក្ខខ្ទាំងណាស់ ថ្ងៃមួយ មានសត្វសារិកាហើរចូលមកក្នុងតំណាក់ទាំងគូ ហង់ជូពៀនទតឃើញក៏ចងជាក់ឃ្លោង ក្បែរទុកនៅជញ្ជាំងប្រែបបផ្អប តំណាក់មានសេចក្តីថា:

ឱទឹកដប់បានរីមានស្អាត      គឺប្រាំប្រាសាទមហាក្សត្រា
ព្រះបៅឡើងនេតជាបិតា      ករុណាប្រោសប្រាណប្រទានឲ្យ ។
យើងជាពជបុត្រមួនកុមារ      ត្រប់ត្រង់រដ្ឋាតទៅក្រោយ
ឥឡូវយើងមកសោកសុបសោយ      ព្រមះងាយព្រះវរពជមាតា ។
ព្រោះគេទាំងឃាតបំបាក់មុខ      ធ្វើរោសងាក់គុកក្នុងប្រាំងប្រា-
សាទសមដូចសត្វសេកសារិកា      ខ្ទោចផ្សាក្នុងទ្រុងស្ទុងវិញ្ញាណ ។
ឱអ្នកកាផ្ការនាហ៊ានមុខ      តតាំរពុកយើងមែនមាន
ចិត្តសត្យសុចរិតគួរគិតធ្យាន      ជួយយើងឲ្យបានរួចទុក្ខា ។
ដ្បិតក្នុងទ្រុងយើងដូចភ្លើងឆេះ      ឈ្លួលឈឺធុរប្រេះព្រាតធ្យួផ្សា
បើបានសងសឹកស្រេចកាលណា      យើងមហាអគុណជូនអ្នក ។

ចំណែកតាំងតុតែងប្រើបំរើទៅស៊ើបស្ដាប់ការនៅទីព្រះតំណាក់ ដែលបង្ខាំងហង់ជូពៀននោះជារឿយៗ ដើម្បីឲ្យដឹងថាគំនិតហង់ជូពៀននោះនឹងគិតដូចម្ដេចខ្លះ ។ លុះបំរើទៅលបមើលឃើញពាក្យឃ្លោងចងទៅ

បង្អួច ក៏លួចស្រាយយកទៅបង្ហាញតាំងតុ ។ បានមើលដឹងសេចក្ដីក៏ខឹងណាស់ថា ហាងដូពៀនធ្វើពាក្យឃ្លោងទុកនេះប្រាថ្នានឹងបង់កេមនុស្សទំ-នុកទុកចិត្តមកធ្វើសងសឹកយើងវិញ ឥឡូវបើយើងនឹងសម្លាប់ចេញ ក៏មិនមានអ្នកឯណានឹងគេហានិន្ទាថាយើងអាក្រក់ គិតហើយតាំងតុក៏បង្គាប់លីយូឲ្យនាំពេជ្ឈឃាដ ១០ នាក់ទៅសម្លាប់ហាងដូពៀននឹងព្រះនាងហោហៅនូវពួកព្រះស្នំទាំងអស់ចេញ លីយូនោះមិញ ក៏ទទួលបង្គាប់នាំពេជ្ឈ-ឃាដទាំង ១០ នាក់ទៅបើកទ្វារតំណាក់ហើយចូលទៅ ពួកស្នំក្រឡេកឃើញ ក៏ចូលទៅទូលហាងដូពៀន ៗ ក៏ស្លុតព្រះទ័យភ័យណាស់ លីយូចូលទៅដល់ ក៏ឈរហុចពែងស្រាដាក់ថ្នាំបំពុលឲ្យហាងដូពៀនសោយ ហាងដូពៀនសួរថាអ្វី? លីយូតបថា មហាឧបរាជយល់ឃើញថា ឥឡូវនេះ ស្រុកទេសជាសុខរាបទាបហើយ ទើបឲ្យទូលព្រះបង្គំយកស្រានេះមកថ្វាយឲ្យទ្រង់សោយ ៗ

ព្រះនាងហោហៅបានឮដូច្នោះ ក៏ងឿងឆ្ងល់ក្នុងព្រះទ័យណាស់ ទើបត្រាស់សួរទៅថា តាំងតុឲ្យយកស្រាមកថ្វាយព្រះរាជបុត្រយើងសោយនោះ យើងក៏មានសេចក្ដីត្រេកអរនឹងគុណលោកណាស់ តែថាត្រូវខ្ញុំអ្នកដែលកាន់ស្រាមកនោះ ផឹកមុនឲ្យយើងឃើញសិន សឹមយើងឲ្យព្រះរាជបុត្រយើងសោយខាងក្រោយ លីយូឮពាក្យដូច្នោះក៏ខឹងណាស់ ក៏ស្រែកហៅពេជ្ឈឃាដ ឲ្យយកគ្រប៊ីនឹងសោប្រវ៉ាក់មកបោះទម្លាក់ទុកចំ-

ពោះមុខហើយថា មហាឧបរាជឲ្យយកស្រាមកថ្វាយឲ្យសោយ បើព្រះនាងហោហៅនែងទទឹងមិនព្រមឲ្យសោយទេ ត្រូវទទួលយករបស់ ២ នេះវិញនឹងយកប្រាក់ឬគ្រាប់ បណ្ដាពួកស្រីស្នំក៏ប្រណម្យដៃលុតជង្គង់ចុះទាំងអស់គ្នាហើយនិយាយនឹងលីយូថា លោកនឹងឲ្យហាងជូពៀនសោយស្រានោះ យើងខ្ញុំទាំងអស់គ្នាទទួលផឹកជំនួសចុះ យើងខ្ញុំសូមតែជីវិតព្រះនាងហោហៅនឹងហាងជូពៀនឲ្យគង់ព្រះជន្មតទៅ លីយូស្រែកគំហកថាមិនគួរឯងរាល់គ្នានឹងមកទទួលស្លាប់ជួសនោះទេ ហើយលីយូក៏យកតែងស្រាបុចឲ្យ ព្រះនាងហោហៅផឹកមុន ព្រះនាងមិនព្រមទទួលសោយសោះ ក៏មានឱបន្ទូលទ្រគោះរំលើកថា ព្រោះតែអាហូជិនជាបងអញរាពេញជាមនុស្សគិតខុស នាំយកពួកអាហោរទូរយសចូលមកក្នុងព្រះរាជឋានអន្តរាយទើបមានដល់ខ្លួនអញនឹងព្រះរាជបុត្រក្នុងគ្រានេះ ។

## សាមកុកវគ្គ ទី ៦

**តាំងពីលីយូធ្វើគុតព្រះបាទហាងជូពៀន នឹងព្រះនាងហោហៅ នូវស្រីព្រះស្នំដោយថ្នាំបំពុលលាយនឹងស្រា ។ លុះដល់អួនសៀវជាមេទ័ព ប្រើតួន អ៊ូ ទៅច្បាំងនឹង ហួ យ៉ុង ។**

ឯលីយូទៅឈរកៀនព្រះបាទហាងជូពៀនថា ទ្រង់នឹងយកគ្រាប់ ឬប្រាក់ ក៏ត្រូវយកឲ្យឆាប់ប្រញាប់ទៅ ។ ព្រះបាទហាងជូពៀនឆ្លើយថាខ្លួនយើងនឹងព្រះវរមាតាត្រូវស្លាប់ជាមួយគ្នាក្នុងថ្ងៃនេះ យើងក៏បានដឹងច្បាស់លាស់ណាស់ហើយ ប៉ុន្តែសុំបង្អង់ឲ្យយើងទូលលាព្រះវរមាតា

យើងសិនចុះ ទ្រង់មានបន្ទូលតែប៉ុណ្ណោះក៏ទ្រង់ចូលទៅឧបព្រះបាទាព្រះ-
វរមាតា ហើយក៏ទ្រង់ព្រះកន្សែងថ្ងូរពិលាបសោកាទាំង ២ ព្រះអង្គនៅ
ក្នុងព្រះតំណាក់មុខគ្នាឲ្យអនិច្ចា ៗ លីយូស្រែកថា ដែលនឹងស្ងៀម
ព្រងើយនៅដូច្នោះគ្មាននរណានឹងជួយឲ្យរួចជីវិតទេ បើផ្ដាំគ្នាយ៉ាងណា
ឲ្យផ្ដាំផាប់ៗទៅ មហាឧបភជនៅចាំយើងឯណោះព្រះនាងហោហៅ
ឆ្លើយថា អាតាំងតុកជាមេចោរក្បត់ផែនដី ដែលវាឲ្យធ្វើអន្តរាយយើង
ក្នុងថ្ងៃនេះ ទោះបីខ្ញុំអញម្ដាយនឹងកូនដល់នូវសេចក្ដីស្លាប់ចំពោះមុខទេវ-
តានឹងមនុស្ស ក៏អញមិនមែនកោតសរសើរវាដែរ ទាំងអាលីយូសោត
ក៏វាជាពួកក្បត់ដូចគ្នា វាក៏មិនមានសេចក្ដីចំរើនប៉ុន្មាន យូរទៅគង់មានគេ
សម្លាប់វាវិញជាប្រាកដ ៗ លីយូបានឮដូច្នោះ ក៏ឈឺចិត្តណាស់ ស្ទុះទៅ
អូសកន្ត្រាក់ព្រះនាងហោហៅដៃម្ខាង ១ ទៀតហូតកន្ត្រាក់នាងស្នំទាញទៅ
ក្រៅផ្ទា ហើយឲ្យពេជ្ឈឃាដចងរឹតព្រះនាងហោហៅនូវស្រីព្រះស្នំ
ទាល់តែស្លាប់ហើយលីយូក៏ត្រឡប់ចូលទៅចាប់ព្រះបាទហងជូពៀនទៀត
ហើយចាប់ប្រាកចូលទៅក្នុងបំពង់ក ក៏ទ្រង់ទីវង្គតក្នុងទីនោះ ៗ ស្រេច
ហើយទើបលីយូបង្គាប់ឲ្យនាំព្រះសពនោះ ទៅកប់ចោលក្រៅក្រុងទាំង
អស់ លីយូក៏វិលត្រឡប់មកជំរាបតាំងតុ ៗ មានសេចក្ដីត្រេកអរណាស់ក្នុង
ខណៈនោះ តាំងតុមានសេចក្ដីកំរើបចិត្តគិតធ្វើការអាក្រក់ផ្សេងៗមិនមាន
រអែងក្រែងខ្លាចអំណាចអ្នកឯណា ចួនកាលពេលយប់ ក៏ចូលទៅដេក

លើព្រះទែនដែលព្រះបាទឡេនតេទ្រង់ធ្វើ ហើយលបលួចព្រះស្នំស្រីស្កា
រួមវេណីជាទីត្រេកត្រអាល ។

. អំណើះតមកតាំងតុ ក៏លើកព្យុហទ័ពចេញទៅស្រុកយ៉ុងសៀ
ហើយឱ្យទាហានព័ទ្ធកំផែង ចូលទៅក្នុងស្រុករើជញ្ជូនយករបស់ទ្រព្យ
ហើយសម្លាប់ម្ចាស់ផ្ទះប្រុស ៗ ចេញជាច្រើន ចាប់យកស្រីមកទុកជា
ឈ្លើយ ហើយឱ្យកាត់យកក្បាលមនុស្សស្លាប់នោះផ្ទុកជិះនឹងរទេះត្រឡប់
ចូលមកទីក្រុង ហើយឱ្យស្រែកអាក្រោសតាមផ្លូវផ្សារថា យើងលើក
ទ័ពទៅចាប់ពួកអាចោរកំណាចបាន កាត់ក្បាលយកមកជាច្រើនណាស់
លុះធ្វើដូច្នេះហើយក៏ឱ្យយកទៅគរដុតចោលទាំងអស់ ឯទ្រព្យរបស់ដែល
រឹបយកបានមក ហើយនឹងស្រី ៗ នោះក៏ចែករំលែកគ្នាជាសម្រាប់ទាហាន
ទាំងពួង ។

ឯង៉ៅហ៊ូជាទីមន្ត្រីធំ លុះឃើញតាំងតុប្រព្រឹត្តសេចក្ដីអាក្រក់ខ្លាំង
ក៏តាំងតែមានចិត្តនោះក្តួលក្តៅណាស់ គិតនឹងសម្លាប់តាំងតុមិនលោះ ១
វេលា លុះគន្លងមកថ្ងៃ ១ នោះ ង៉ៅហ៊ូយកកាំបិតសៀតបង្កប់ក្នុងអាវ ហើយ
ចូលទៅកាន់ទីគាល់ ទទួលពេលនោះតាំងតុចេញមកដល់ទ្វារកំផែង ង៉ៅ-
ហ៊ូ ដកកាំបិតបង្កប់ចេញនឹងចាក់តាំងតុ ៗ ក្រឡេកទៅឃើញទាន់ការពារ
បាន លីប៉ោ ក៏ស្ទុះចូលទៅជួយចាប់ ង៉ៅហ៊ូ ជាប់ហើយថា ហេតុម្ដេចទើប
ខ្លួនមកគិតធ្វើគំនិតអាក្រក់ ចាក់មហាឧបរាជជាបិតាយើងដូច្នេះ ង៉ៅហ៊ូ

មិនខ្លាចសេចក្ដីស្លាប់ប្រាប់ថា តាំងតុធ្វើការអាក្រក់ណាស់. អញមានបំណងនឹងកាត់យកក្បាលផ្ដាល់ឲ្យទៅតាមនឹងមនុស្សឃើញជាក់ច្បាស់ក្នុងលោកិយ តាំងតុបានឮសំដីក៏រឹតតែខឹងពន់ប្រមាណ បានបង្គាប់ពេជ្ឈ-ឃាដឲ្យនាំខ្លួនហើយទៅអារពន្ទះសាច់ផ្ដាច់ជីវិត ពេជ្ឈឃាដក៏ស្ទុះចូលចាប់យកខ្លួន ហើយៗ មិនមានតក់ស្លុតរំជួលខ្លាច ស្រែកជេរតាំងតុទាល់តែពេជ្ឈឃាដកាប់ផាច់ខ្យល់ស្លាប់ តាំងពីនោះមកតាំងតុឲ្យទាហានវេនរក្សាព្រះបរមរាជវាំងយ៉ាងមាំមួនជាងពីដើម ។

ឯអ្នកសៀវដែលជាទីចៅហ្វាយស្រុក ពុតហៃ បានល្បីឮកិត្តិស័ព្ទថា តាំងតុធ្វើការអាក្រក់សម្លាប់ព្រះនាងហោហៅ នូវព្រះបាទហាំងជូពៀនជាម្ចាស់ផែនដីក្ស័យព្រះជន្មដូច្នោះ ក៏តែងសំបុត្រជាសំងាត់ទៅដល់អងអ៊ុនដែលជានាហ្មឺននៅក្នុងក្រុង ក្នុងសេចក្ដីសំបុត្រនោះថា សព្វថ្ងៃនេះតាំងតុកំរើបចិត្តគិតការក្បត់ផែនដី ទឹងរកនាហ្មឺនមុខមន្ត្រីណាមានប្រាជ្ញាឈ្លៀវឆ្លាតគិតសង្គ្រោះរំលាងបំផ្លាញតាំងតុ ចេញគ្មាន ដែលយើងចេញទៅនៅខែត្រក្រៅក្រានេះ នឹងបានដេកធ្មេចមិនគិតក៏ទេ គឺខំឧស្សាហ៍បញ្ចុះបញ្ចូលសេនាទាហាន នឹងរៀនបង្គាប់ឲ្យស្ទាញស្ទាត់ក្នុងការសង្គ្រាមមិនលោះមួយវេលា ព្រោះជាសេចក្ដីកតញ្ញូនឹងផែនដី ដើម្បីយកអាសាកំចាត់តាំងតុជាសត្រូវរាជសម្បត្តិនោះចេញ បើអ្នកណាយល់ត្រូវតាមគំនិតចិត្តយើងហើយ កុំគប្បីព្រងើយកន្ដើយគិតការខាងក្នុងឲ្យមាំមួនចុះ យើងនឹងលើកកងទ័ពចូលមកធ្វើការឲ្យបានសម្រេចដោយងាយ ។

អង់អ៊ុនបានយល់ក្នុងសេចក្ដីសំបុត្រនោះគ្រប់ប្រការ ក៏មានសេចក្ដីវិតក្កវិចារៈមិនមានគេចសោះ លុះកន្លងមកថ្ងៃមួយជាពេលចេញចាកទីគាល់ អង់អ៊ុន ក៏រង់ចាំនិយាយនឹងនាហ្មឺនចាស់ទុំទាំងពួងថា ថ្ងៃនេះត្រូវការនឹងអញ្ជើញអស់លោកទៅពិសាក្រយាៈនៅឯផ្ទះខ្ញុំ ជាកំសាន្តសប្បាយ បណ្ដានាហ្មឺនទាំងឡាយក៏ស្រុះស្រួលបបួលគ្នាទៅស៊ីលៀងលើផ្ទះអង់អ៊ុន កាលដែលប្រជុំព្រមគ្នានឹងបរិភោគអាហារនោះ អង់អ៊ុន ក៏អង្គុយយំជាទុក្ខខ្សឹកខ្សួល នាហ្មឺនទាំងពួងក៏ផ្អើលផ្ដួលទៅសួរថា៖ លោកយំសោកជាទុក្ខព្រោះអ្វី? អង់អ៊ុន ឆ្លើយថា តាំងតុចូលមកនៅក្នុងស្រុកក្រុងធ្វើការទុច្ចរិតសម្លាប់ព្រះនាងហោហៅ នូវព្រះបាទហាន់ឆ្ងុះពៀនក្សយព្រះជន្ម ខ្ញុំមានសេចក្ដីក្ដៅចិត្តណាស់ ឧបមាដូចជាដេកលើគំនរភ្លើង ខ្ញុំសំឡឹងទៅមិនឃើញអ្នកឯណា នឹងជួយគិតទំនុកបំរុងផែនដីឲ្យបានសេចក្ដីសុខសោះ ខ្ញុំគិតឃើញដូច្នោះទើបយំជាទុក្ខ នាហ្មឺនទាំងពួងបានស្ដាប់ ក៏មានសេចក្ដីសង្វេគស្រក់ទឹកភ្នែកយំសោកទាំងអស់គ្នា ។

មានតែ ចោចោ ម្នាក់ក្រោកឡើងឈរទះដៃសើច ហើយថាចោលម្សៀតអស់លោកនាហ្មឺនចាស់ទុំប្រជុំ គិតការប៉ុណ្ណោះមិនផុះផាយហើយមកបបួលគ្នាអង្គុយយំ ។ អង់អ៊ុនខឹងណាស់និយាយតបទៅចោចោថាជីតានឹងបិតារបស់អ្នកឯងក៏ជានាហ្មឺនបានស៊ីប្រាក់បៀវត្សមកពីដើមដែរ ម្ដេចអ្នកឯងមិនមានកតញ្ញូនឹងផែនដី យើងគិតការនឹងបំផ្លាញរំលាងតាំងតុ

ចេញ តែថាតាំងតុមានសេនាទាហានខ្លាំងពូកែច្រើនណាស់ យើងជំរះមិនផុះផ្កាយទើបឈឺចិត្តអង្គុយយំដូច្នេះ ហេតុអ្វីអ្នកឯងមកក្លែងទះដៃសើចបំអកឡកឲ្យយើងដូច្នេះ? ចោគោឆ្លើយថា អស់លោកចាស់ទុំសុទ្ធតែជានាហ្មឺនតមកពីផែនដីមុនមានចិត្តគិតនឹងទុកបំរុងផែនដីជាច្រើនកដ ហេតុម្តេចក៏គិតនឹងកំចាត់តាំងតុប៉ុណ្ណោះមិនបាន នាំគ្នាអង្គុយយំខ្ញុំឃើញដូច្នេះបានជាអស់សំណើច ឯជីតានឹងបិតារបស់ខ្ញុំជាខ្ញុំរាជការមកពីដើមនោះខ្ញុំក៏គិតកតញ្ញូដល់ផែនដីជាដរាប ប៉ុន្តែតាំងតុនោះបើខ្ញុំនឹងគិតសម្លាប់ចេញវេលាណាក៏បាន ៗ

អង់អ៊ុនថា អ្នកឯងនិយាយដូច្នេះ យើងមិនទាន់យល់ឃើញផងទេ ដែលនឹងគិតសម្លាប់តាំងតុនោះ ត្រូវគិតយ៉ាងម្តេចចូរអធិប្បាយឲ្យយើងស្តាប់សិនមើល ៗ ចោគោឆ្លើយតបថា ខ្ញុំត្រូវធ្វើសេចក្តីព្យាយាម ចូលទៅធ្វើខ្លួនឲ្យតាំងតុប្រើប្រាស់ទាល់តែស្និទ្ធទុកចិត្តប្រាកដ មិនមែនឃើញដោយលាភសក្ការៈអ្វីៗ ព្រោះគិតកតញ្ញូដល់ផែនដីប្រាថ្នានឹងសម្លាប់តាំងតុឲ្យបាន តែថានៅទាស់ព្រោះគ្មានអាវុធកាន់កំដរដៃ ខ្ញុំដឹងថាគ្រប់ខ្លីរបស់លោកមាន បើលោកឲ្យទានគ្រប់នោះមកខ្ញុំខ្លី ខ្ញុំនឹងស៊ៀតបង្កប់ជាប់នឹងខ្លួនចូលទៅដល់តាំងតុ ហើយនឹងសម្លាប់កាត់យកក្បាលមកជូនលោកឥឡូវនេះ អង់អ៊ុនបានស្តាប់ដូច្នោះ ក៏មានសេចក្តីត្រេកអរណាស់ ទើបក្រោកឡើងលុតជង្គង់គំនាប់ចោគោហើយចាក់ស្រាឲ្យចោគោផឹក ៗ (ម.៩៨)

# រឿងៈកាកគកុលកុមារៈ

អ្នកឧកញ៉ា ព្រះឃ្លាំង នង រៀបរៀង

(តមក)

ខ្ញុំមើលស្គាល់ជាក់ ចិញ្ចៀនដែលពាក់ ពិតពុំសង្ស័យ ទើបខ្ញុំបរបួល
មកទូលក្សត្រថ្លៃ ឲ្យជ្រាបព្រះទ័យ តាមតែមេត្តា ៗ ស្ដេចស្ដាប់ទំនូល
រាជបុត្រីទូល ពីព្រះសុណិសា មកដល់ស្រះស្រង់ ស្ដេចទ្រង់ចិន្ដា
ត្រេកសោមនស្សា- ទរទើបបង្គាប់ ៗ ជាហៃសេនា ទាំង៩ម្ម៉ា រួស
រៀបប្រដាប់ គ្រែព្រះរាជយាន មាសមានសម្រាប់ គ្រឿងក្ងស់
ផ្គាប់ គ្រឿងពារណ៍ពស្ដ្រា ៗ ឲ្យល្អសមគួរ ចេញទៅទទួល យក
កូនប្រសា អញពីកំពង់ ស្រះស្រង់រង់ថ្វា នាំមកម្ម៉ា កុំឲ្យផ្សូផ្សង ៗ
សេនាស្ដែងស្ដាប់ ស្ដេចទ្រង់បង្គាប់ ប្រាប់គ្នាពុំលង់ រៀបគ្រឿងប្រដាប់
សម្រាប់ស្ដេចទ្រង់ នាំនាំត្រេបត្រង់ ដល់ឆ្នេរស្រះស្រី ៗ យកមហា-
បុរស រត្នរូបស្រៀបស្រស់ លើសលែងលោកិយ ទើបអស់សេនា
យោធាមន្ត្រី បរបួលអភី- រទររន្ទ្វា ៗ ទូលថាសូមទាន ពីមហា-
ក្សត្រក្សាន្ត ជាព្រះបិតា- ធិរាជឧត្ដម ប្រើខ្ញុំករុណា យកព្រះកូសា
ព្រះពស្ត្រដែលទ្រង់ ៗ ព្រះរាជទានឲ្យ មកម្ចាស់មាន រូបរត្នវរ-ង្សា
ស័ក្តិស្មើសម ឲ្យម្ចាស់ទ្រង់ ស្រេចហើយឲ្យគង់ លើរាជយានទៅ ៗ
ព្រះពោធិសត្វ មហាបុរសរត្ន វិសេសបំពៅ ទទួលពស្ត្រា ក្ងមាស

មាសផ្កៅ ល្អះល្អឥតសៅ អ្នកយកមកថ្វាន់ ។ សក្តិសមសោភា ហាក់
អន្ទិទេព្តា យានយាសឡើងគង់ លើព្រះរាជយាន មាសមានពលពង្ស
សេនាចតុរង្គ ហែៗ រៀងរាយ ។ បើកបាំងក្ងស់ក្ងំ ខ្លន់ខ្លស់ត្រសុំ
ត្រស័កត្រសាយ តសៀករំហើយ រំភើយព្រះពាយ ទៅទៀបបន្ទាយ
រាជវាំងក្សត្រា ។ អ្នកបរចុះប្ពាន ពីព្រះរាជយាន យានយាសលីលា
ឡើងលុះលើឋាន ពិមានរាជា ក្រញូក្រាបវន្ទា ប្រណម្យនិត្យនៅ ។
កាលណោះក្សត្រា ជាព្រះបិតា គយគន់មើលទៅ យល់ពោធិសត្វ
រូបវត្តល្អេញល្អៅ ព្រះភ័ក្ត្រឥតសៅ ហ្មងមានរស្មី ។ ដូចចន្ទ្រវែងចាំង
ក្ដៅផ្ទុកអស់ទាំង អាកាសនភី ឥតទីអ្នកស្មើ លើសលើលោកិយ៍ ប្រុស
នៅដែនដី ផ្ទប់ផ្ទឹមមិនមាន ។ ទ្រង់ព្រះចិន្តា ក្នុងព្រះទ័យថា ឧបុត្រ
បុរាណ សំណាងកូនអញ សំឡាញ់មកបាន ស្វាមីមិញមាន ធោម
ធាយសោភា ។ គាប់គួរជាគូ ល្អល្អះត្រឹមត្រូវ សាក់សំនឹងគ្នា ស្តេច
គិតឯងអរ សាទរមហិមា ត្រេកត្រាស់សួរថា ហៃបុត្រពិសី ។
អាត្មាកចង់ដឹង ចង់ជ្រាបដំណឹង ដំណើរអំពី ព្រហ្មទត្តពាលា ហៅ
បាទៅថ្វី បានជាបុត្រី រត់មកតើម្ដេច ។ កាលណោះព្រះពង្ស ពូជ
ពោធិវ - ង្សាសក្តិសពេជ្ញ ឧនអង្គបង្គំ ប្រណម្យស្រលស្រេច ទូលទៅ
សម្ដេច ព្រះវរបិតា ។ ពីនាងនាដរត់ ព្រោះព្រះព្រហ្មទត្ត កាចគិត
ឫស្យា ត្រាស់ឲ្យមកហៅ ខ្ញុំទៅកោក្កា សឹងស៊ុតមានទា លាយនឹង

បំណាំ ៗ ខ្ញុំបរិភោគ ស្រេចហើយលុតលា មកមណ្ឌលទី រកនាង ពុំឃើញ សោកសល់សែនទុក្ខ ដឹងដើមសេចក្តី ដោយក្តែប្រាប់ប្រា ៗ ថានាងកល្យាណ ទើងនៅពុំក្ស័ន្ត រត់មកស្រុកឆ្ងាយ ទើបខ្ញុំត្រេចមក តាមរកធោមធាយ ធ្ងន់ផលសាសាយ រួចដល់ត្រើយត្រាន ៗ ទើប ក្តែមរណា គ្មាតនាំមាគ៌ា ៧យោជន៍បាន គ្មាតនោះសោតស្លាប់ ស្រេច ស្រាប់តែមាន ក្អែកនាំផ្លូវបាន ៧យោជន៍សល់ ៗ ក្អែកនោះសោត ស្លាប់ មានរុយមួយប្រាប់ ណែនាំដើរដល់ ៧យោជន៍ឆ្ងាយ បម្ងាយ ទូពិល រុយស្លាប់ទៀតយល់ អំពិលអំពែក ៗ មួយមានធរី រុងរឿង រស្មី អស្ចារ្យបំផ្លែក ល្អដូចផ្កាយព្រឹក ភ្លឺផ្ទេកពន់ពេក កណ្តាលផ្ទៃ មេឃ លើសលែងគាក ៗ នាំខ្ញុំត្រេចត្រង់ មកដលស្រះស្រង់ ទ្រង់ ព្រះករុណា ពិសេសៈហើយហោះ ផ្តោះទៅសួគ៌ា សមអង្គទេព មែន មិនដទៃ ៗ បពិត្រអម្ចាស់ ខ្ញុំលំបាកណាស់ កាលដើរដោយព្រៃ ម្នាក់ឯងពុំគិត ជីវិតក្សេក្ស័យ សូមជ្រាបព្រះទ័យ ពុំបោរមេត្តា ៗ ស្តេចស្តាប់ពាក្យពី ពួដពង្សរោធី ទូលទើបក្សត្រា ជ្រាបសព្វសេច ក្រេច ហើយស្តេចអន្ទិច្ចា សង្វេគចិន្តា អាណិតពោធី ៗ ទើបស្តេច ត្រាស់ឲ្យ រៀបក្រយាស្ងោយ ភោជន៍ភ័ស្តុពិសី ពិសាត្រកាល អាហារ ថ្មោងថ្មី មកឲ្យពោធី - សត្វសោយស្កប់ស្កល់ ៗ កាលណោះក្សត្រា ទ្រង់ព្រះចិន្តា , ដោយព្រះយោបល់ ជាបុត្រប្រសា សោភាទិមិល

មានរិទ្ធិពល ប្ញតរិទ្ធី ៗ គិតគួរតែអញ យកធ្នូឲ្យបាញ់ លេងលង បារមី ទើបបើកព្រះសូរ បន្ទូលទៅខ្ញុំ ថាហៃមន្ត្រី កំណាន់រក្សា ៗ ចូរទៅបរទៅ យកធ្នូសិល្បនៅ សរសក្តិថ្ងៃថ្ងា សែងមកឲ្យឆាប់ ប្រ-ញាប់ម្នម្នា មន្ត្រីលុតលា ចុះបររួសរាន់ ៗ ប្រើនាយប្រាប់ពល ហៅគ្នារបស់ ចូលមកបំពាន់ កាន់ឈើស្នែងទៅ សែងធ្នូកំណាន់ រត់រួសរន្ទាន់ ដល់ថ្វាយក្សត្រា ស្តេចទតទៅយល់ ធ្នូជ័យមកដល់ បើកបន្ទូលថា ហៃបៅគោគកុល និម៌លៈសោភា កូនអើយចូរបា បាញ់ធ្នូនេះមើល ៗ បង់ដឹងរិទ្ធី ពលពលបារមី បាបុត្រប្រសើរ លេងលងចេស្តា ឲ្យអាពុកមើល ឲ្យដឹងដំណើរ កាលគ្រានេះម្តង ៗ

### បទពំនោល

ព្រះពោធិសត្វច្បាស់ច្បង ក្រញ្ញក្រាបរាប់រង ទទួលព្រះរាជឱង្ការ ៗ លុតលាយាត្រាត្រអាល ទៅដល់កណ្តាល ទីមុខព្រះលានក្សត្រា ៗ ទើបអ្នកឈរឈោងហត្ថា យកធ្នូសរថ្វា ត្រកាសត្រីលេងលង ៗ យល់ហាក់ស្រាលក្រៃកន្ទង ដូចកល់ស្រីផង កាន់ជងដំពេចសំឡី ៗ រាយរាត់ដំឡើងឆាប់ខ្ញី និរកិតឃ្លាតខ្ញី ទើបយកសរមកផ្គាប់ ៗ បែរបាញ់ចេញទៅឮសព្ទ ស្ទួសរហាក់ផ្កាប់ ក្រឡាប់ទាំងភូមិកពភារ ៗ ឮទៅដល់ក្រៅចក្រពាល កំពែងចក្រវាល ហាក់ដូចនឹងផ្កាប់ក្រោមទ្រុឌ ៗ ពុះពោរជន់ដោរសមុទ្រ សុមេរុបពិត កក្រើករំពើកញាប់ញ័រ ៗ លាន់

ពុទ្ធិអស្ចារ្យ រំពឹងខ្វរខ្វារ ដូចសែនទ្រូះគណនា ។ អស់រាស្ត្រភិតភ័យ
តក្កមា លុះលាន់មាត់ថា ឱះអះពះស្វាប់ទេះម្តង ។ ស័ត្វអ្វីព្ទក្រែកកន្ទង
ស្ញៀរស្ញុះដំរពង ស្ញើរទឹងបែកខ្ទឹងកាំមាំ ។ រាស្ត្រខ្វះដឹងហើយប្រាប់ថា
ផ្សិតព្រះសុណិសា ក្សត្រាធិរាជថ្កើងថ្កាន ។ ចុះញាំធ្ចនៅមុខព្រះលាន
គាណអើយកុំគាណ ភិតភ័យខ្លាចក្សយជន្ទា ។ អស់មុខមន្ត្រីយោធា
យន់យល់ចេស្តា ឧកាពព្រះអង្គលើសក្រៃ ។ សឹងកោតស្ញប់ស្ញែង
ទីទៃ ត្រើសព្រមជួយជ័យ ចំរើនព្រះពរអឺអឹង ។ សិល្បសរសក្តិ
សោតវិលវឹង វិលមកនៅទីង បំពង់ដែលដាក់និក្សេទៅ ។ ទើបអ្នកលើ
លាឡើងទៅ បង្គំគាល់ហ្វៅ នៃព្រះជនកក្សត្រា ។ ស្តេចយល់
រិទ្ធិពលចេស្តា បុណ្យបុត្រប្រសា ប្រសើរប្រសប់សិល្បសោយ្យ ។
ព្រួចព្រឺព្រើសព្រះកត្រូថ្ងៃ ត្រេកត្រូវព្រះទ័យ រំពៃរំពឹងរកកល ។
ដោយព្រះទិព្វញាណយោបល់ បង់ល្បងឲ្យយល់ អំពល់អំពើកម្រ ។
ឲ្យយករទេះពីរមក៏ មួយដាក់គ្រាប់ល្ង មួយទុកទទេទនិត្យនៅ ។ ទើប
ស្តេចបើកបន្ទូលទៅ ត្រាស់ថាហៃចៅ គោកកុលជាបុត្រសំឡាញ់ ។
ចូរបាចសព្វាហ៍អស់អញ រើសគ្រាប់ល្ងចេញ ពីក្នុងរទេះនេះទៅ ។ ដាក់
រទេះទទេនៅ ម្តងមួយគ្រាប់ទៅ ឲ្យអស់ក្នុងថ្ងៃនេះប៉ាត់ ។ ឯអង្គពុជ
ពង្សព្រទ្ធរត្ន ក្រញាំក្រាបប្រណិបត្ត ទទួលព្រះរាជអាជ្ញា ។ អ្នកគិត
តាំងចិត្តចិន្តា ប្រណិធានសច្ចា នឹកដល់ព្រះឥន្ទ្រធិបតី ។ ជាឲអស់
បុណ្យបារមី អញសាងអំពី ម្តងអសង្ខេយ្យា ។ បើអញទឹងបាន

ត្រាស់ថា៖ អង្គព្រះសម្មា-សម្ពុទ្ធប្រាកដទៀងទាត់ ៗ ផ្លាស់ឆ្លងការ
ភូមិភពវដ្ត-សង្សារនាំសត្វ ដាក់ដល់នគរនិព្វាន ៗ សូមឲ្យព្រះឥន្ទ
ហោះឆ្វាន មកជួយឲ្យប្រាន សម្រេចដូចចិត្តប្រាថ្នា ៗ តេជៈហេតុ
បារមីគា ពន្ធកសាស្ដា ក្ដៅដល់មណ្ឌលកម្ពល ៗ សិលាអាសនាក្ដើង
ថ្កល់ ទិព្វទីមណ្ឌល សម្ដេចអមរិន្ទឥន្ទ្រា ៗ បានបែរបើកទិព្វចក្ខុ
យង់យល់ព្រះមហា បុរសព្រួយព្រះហ្ឫទ័យ ៗ ស្ដេចហោះចុះចាក
ឋានត្រៃ-ត្រឹង្សត្រេចត្រង់ញ បុរីសត្ថភូជភាដា ៗ ប្រញ្ញប្រាណ
ប្រឹងប្រែកាឡា និមិត្តកាយា ដាក់ផ្សែរមោចខ្ទៅខ្វល ៗ ពេញ
ពាសដេរដាសទង្វល ពាំល្ងដាជួរ ដញ្ញូនតីរទេះបេញ ៗ ដាក់
ទៅរទេះមួយមិញ មួយរំពេចពេញ ពុំសល់ដល់មួយគ្រាប់នៅ ៗ
ព្រះវរបិតាបមហៅ ស្ដែងស្ដេចទតទៅ យល់ជាអស្ចារ្យពេកពន់ ៗ
សេនាយោធាមុខម-ន្ត្រីប្រជាជន យល់ហើយសឹងកោតបេស្ដា ៗ
ស្ញែងបុណ្យស្ញែងបារមីគា សឹងឲ្យសព្ទសា-ធុការបំរើនព្រះពរ ៗ
កាលណោះសម្ដេចព្រះវរ-បិតាសាទរ ព្រះអង្គទ្រង់ព្រះចិន្តា ៗ
ចង់លបង់ល្បងប្រាជ្ញា បុណ្យបុត្រប្រសា ប្រសើរឲ្យបានបីដង ៗ
ស្ដេចប្រើនាយព្រះក្រាលផង ក្រាលព្រំប្រៀមបង រនាំងបាំងព្រះ
សន្ទិយា ៗ ស្រេចឲ្យអស់អង្គជីតា ពាំអង្គា លីលាឡើងមកគាល់
គង់ ៗ រៀបរៀងពល់កាយតីកុង បន្ទុបតែចុង ម្រាមព្រះហស្ថមកក្រៅ ៗ

# ពន្លឺអាស៊ីទ្វីប

ហ្លួងទិពន្ធមន្ត្រី ញ៉ុក - ថែម ប្រែ - រៀបរៀង

(តមក)

---

ក្នុងខណៈនោះ ព្រះសិទ្ធាថ ទ្រង់យាងស្រូកទៅជួយលើកមនុស្សជម្ងឺឡើង ដោយព្រះហស្តដ៏ទន់ភ្លន់មានមេត្តា ទ្រង់សន្សឹមៗ ដាក់ក្បាលអ្នកជម្ងឺលើព្រះជាណុ រួចទ្រង់ស្ទាបអង្អែលបំបាត់សេចក្ដីឈឺចាប់ ហើយទ្រង់មានព្រះបន្ទូលសួរថា នៃបង ចុះរាល់ឈឺចាប់យ៉ាងណា កើតពេកអ្វី? ហេតុអ្វីក៏ក្រោកមិនរួច? នាយឆន្នៈ, ហេតុអ្វីក៏គាត់ហត់បរះនទៀលទិ-យាយមិនរួចមានអាការមុខគួរឲ្យអាណោចអាធម្មម៉្លេះ?—

នាយសារថីក្រាបទូលតបថា "ឱព្រះមហាក្សត្រថ្លៃ, មនុស្សនេះកើតពេកប៉ែស្ដមួយយ៉ាង ដែលបណ្ដាលឲ្យធាតុទាំងពួងថយកម្លាំងរលត់ទៅ, ឈាមដែលតែងហូរទៅតាមសព្វសរសៃដូចជាប្រឡាយទឹកនោះ ឥឡូវកើតអាក់អួលជុតជាលក្លាយទៅជាក្អក់ក្អើងឡើង ប៉ែះដូងដែលធ្លាប់កំរើក មានរយៈស្មើគ្នាតាមធម្មតា ឥឡូវប្រែជាកំរើកញាប់ក៏មានយឺតៗក៏មាន ហាក់ដូចជាស្គរដែលគេវាយមិនត្រូវតាមចង្វាក់ ដុំសាច់គ្រប់ៗគាត់ធូរថយទៅដូចខ្សែធ្នូដែលធូរ, កម្លាំងពលរបស់គាត់ថយខ្សោយអស់ទៅពីកំភួនជើង ចង្កេះនិងករបស់គាត់ហើយ, បុកពាហីហាននិងការរើកពាយតាមធម្មតារបស់មនុស្សផុតរបូតអស់ទៅហើយ; នេះហើយគឺមនុស្ស

ឈឺ ត្រូវរោគាព្យាធិកំពុងដុតរោល ។ សូមទ្រង់ទតមើល, គាត់អេះខ្ញាំខ្លួនរបស់គាត់ ដើម្បីដកយកជម្ងឺដំកាត់ចេញ គាត់ខំប្រឹងប្រមះនទៀល ខាំមាត់សង្កៀតធ្មេញដកដង្ហើមប្រដឹតប្រដក ហាក់ដូចមនុស្សឈ្លក់ផ្សែង ។ សូមទ្រង់ទតមើល! គាត់គង់ចង់ស្លាប់ទៅឆាប់ ប៉ុន្តែមិនងាយនឹងស្លាប់ឆាប់ មុនរោគជម្ងឺនោះវាបៀតបៀនឲ្យបានវេទនាជាពន្ទឹកដោយសម្លាប់សរសៃប្រសាទទាំងឡាយឲ្យស្លាប់ទៅមុនជីវិត ហើយកាលដែលអវយវទាំងពួងរលត់ទុក្ខវេទនាហើយ ទើបការឈឺចាប់ចេញចាកខ្លួនគាត់ ហើយចាប់បៀតបៀនទីដទៃទៀត" ។ "ឱ! ព្រះម្ចាស់ថ្លៃ, មិនសមគួរនឹងការដែលព្រះអង្គលើកបីត្រកងខ្លួនគាត់ទេ, ដ្បិតជម្ងឺនេះអាចឆ្លងរាលដាលដល់ព្រះអង្គផង" ។

ព្រះរាជកុមារទ្រង់ជួយលួងលោមបំបាត់ទុក្ខសោកមនុស្សនោះ ហើយមានព្រះបន្ទូលថា "នៅមានមនុស្សដទៃទៀត ដែលមានជម្ងឺឈឺចាប់ដូច្នេះ មានច្រើនដែរឬ? ហើយខ្លួនខ្ញុំអាចទៅជាមនុស្សដូច្នេះដែរឬទេ? ។

នាយសារថីក្រាបទូលស្នងថា "សូមទ្រង់ព្រះមេត្តាប្រោស, ការឈឺចាប់នោះ រមែងកើតមានដល់មនុស្សគ្រប់ជំពូក ដោយអាការរោគផ្សេងៗ គ្នា គឺសេចក្តីឈឺចាប់និងរបួសផ្សេងៗ ព្យាធិ, រោគស្លាប់ជើងស្លាប់ដៃ, ឃ្លង់, រោគគ្រុនក្តៅ, រោគរាកមួល និងបូសកមផ្សេងៗ រមែងប៉ះពាល់ដល់សព្វសត្វ ហើយឆ្លងរាលដាលទៅសព្វអន្លើ" ។

ព្រះរាជកុមារត្រាស់សួរថា "ចុះជម្ងឺដែលកើតឡើង គេមើលក៏មិនឃើញទេឬ? នាយឆន្នក្រាបទូលថា "រោគអស់នោះហាក់ដូចជាអសិរពិសដ៏សាហាវមកចឹកខាំយើង ដោយមិនឃើញរូបរាជាមុន, ដូចខ្លាកាចដែលលាក់ខ្លួនពួននៅក្នុងគុម្ពកន្ទុះ: ក្បែរផ្លូវក្នុងព្រៃធំ សម្ងំចាំឱកាសល្អនឹងលោតទៅចាប់សត្វទាំងឡាយស៊ីជាអាហារ, ឬដូចជារន្ទះដែលធ្លាក់ចុះមក ចួនក៏ត្រូវមនុស្សខ្លះចួនក៏មិនត្រូវ" ។

"ចុះមនុស្សគ្រប់រូបរស់នៅក្នុងអាការគួរស្ងប់ស្ងៀមមែនឬ?

"ឱ! ក្សត្រថ្លៃ មនុស្សយើងរស់នៅក្នុងទំនងដូច្នោះមែន" ។

"ចុះគ្មាននរណាហ៊ានពោលថា: ខ្លួនខ្ញុំដែលជាសុខស្រាន្តរហូត ១ យប់នេះ ដរាបដល់ភ្លឺឡើងវិញ មែនឬទេ! —

"សូមទ្រង់ព្រះមេត្តាប្រោស, គ្មាននរណាហ៊ានរ៉ាប់រងទេ" ។

"ហើយនៅទីបំផុតនៃសេចក្ដីលំបាកជាអនេកប្រការនេះ ដែលពុំចូលមកប៉ះពាល់ មិនឲ្យមើលឃើញ មិនឲ្យដឹងខ្លួន ហើយបណ្ដាលឲ្យមានផល គឺរាងកាយទ្រុឌទ្រោម វិញ្ញាណទុព្វលភាព ឲ្យដល់នូវជរាភាព ដូច្នោះឬ?

"សូមទ្រង់ព្រះមេត្តាប្រោស, បើមនុស្សមានជីវិតយឺនយូរមកដល់ថ្នាក់នេះ តែងតែដូច្នេះឯង" ។

"ប្រសិនបើយើងមិនអាចអត់ធន់អំណាចរបស់វាបាន ឬបើយើងអត់ធន់ទ្រាំទ្រហើយ បើយើងចង់ឲ្យវាផុតរលត់ទៅ ឬបើយើងអត់ធន់

ទ្រាំទ្រ ហើយបើមានអាការដូចជាបុរសដ៏ទុព្វលភាពណាស់នេះ ហើយមិនអាចនឹងមានជីវិតតទៅទៀតបើចង់រស់តទៅទៀត ត្រូវតែចាស់ជរាទៅ ៗ! បើដូច្នេះតើនឹងមានទីបំផុតដូចម្ដេច? —

"សូមទ្រង់ព្រះមេត្តាប្រោស, យើងត្រូវស្លាប់ទៅនៅទីបំផុត" ។

"យើងត្រូវតែស្លាប់ដែរឬ?

— "សូមទ្រង់ព្រះមេត្តាប្រោស, ពិតណាស់, នៅទីបំផុត យើងត្រូវតែស្លាប់ មិនថានៅទិសតំបន់ណា ឬនៅពេលណាទេ, អ្នកខ្លះចាស់ស្លាប់ អ្នកខ្លះគាំងរងទុក្ខវេទនាហើយឈឺស្លាប់ទៅ, ប៉ុន្តែមនុស្សគ្រប់រូបត្រូវតែស្លាប់; សូមទ្រង់ទតមើលចុះ នុះហ្ន៎ សេចក្ដីស្លាប់ដែលគេហែហួសទៅ! ។

គ្រានោះ ព្រះសិទ្ធត្ថកុមារងើបព្រះនេត្រទតមើលទៅទ្រង់ឃើញក្បួនហែមួយ ហែយឺតៗតាមដងស្ទឹង មានមនុស្សស្រែកយំតាមហែផង ខាងមុខក្បួនមានមនុស្សម្នាក់កាន់ភាជន៍ដីពេញដោយរងើកភ្លើង ខាងក្រោយមានពួកញាតិសន្តានគោរក្បាលស្លៀកពាក់កាន់ទុក្ខ ហើយស្រែកខ្លាំងៗថា ឱ! ពមា, ពមា, សូមទ្រង់ស្ដាប់! សូមបងប្អូនជួយអង្វរពមាផង" ។ តបន្ទាប់មក មានមឈូសដាក់សពត្បាញដោយឫស្សីដើងទៅខាងមុខរងស្លុកស្ដឹង មានតែស្បែកដណ្ដប់ឆ្អឹង, ឆ្អឹងជំនីរផតខ្លួន, មាត់ស្មេញប្រឡាក់លាបដោយផង់ក្រហមនឹងលឿង; លុះហែទៅដល់

ផ្លូវបំបែក ពួកអ្នកសែងក៏បង្វិលក្បាលសពទៅខាងមុខ ហើយតាំងស្រែកឡើងថា "ភមា, ភមា" ។ ហើយនាំគ្នាសែងសពនោះទៅមាត់ស្ទឹងដែលមានគំនរឧស ហើយដាក់សពពីលើ រួចគេយកឧសដាក់សង្កត់ថែមពីលើសពទៀត — អ្នកដែលដេកសម្រាកលើដំណេកដូច្នេះ តែងដេកលក់យ៉ាងស៊ប់ស្ងួន ( លែងក្រោក ) ទោះបីត្រូវគ្នា - គេដាក់គប់សង្កត់ក៏មិនធ្វើឲ្យគេភ្ញាក់រលឹកឡើងបានទេ បើទុកដាក់យកទៅហាលខ្យល់ទាំងអាក្រាតកាយក៏ដោយ ក៏តកមានក្ដៅខ្លួន ។ រួចពីនោះ គេនាំគ្នាដុតភ្លើងឡើងទាំង ៤ ទិស ភ្លើងក៏សន្ធើមៗ ឆេះភ្លាវឆាលឡើង ឆេះគំនរឧសមានអណ្ដាតភ្លើង ឆាបឆ្លួលឡើងមួយរំពេចឆាបឆេះរូបអសុភនោះ ហើយស្បែកដ៏ក្រៀមក៏របេះរបកទៅ ហើយដំណាឆ្អឹងក៏ដាច់ធ្លាក់ចេញខ្ចាត់ខ្ចាយ, ទៅទីបំផុត ផ្សែងភ្លើងដ៏ក្រាស់ក៏សន្ធើមៗ រលាយបាត់ទៅ ទុកសល់នៅតែឆ្អឹងសក្បុស — នេះហើយជាសំណល់របស់មនុស្សយើងគ្រប់រូប " ។

ខណៈនោះ ព្រះរាជកុមារមានព្រះបន្ទូលថា "នោះហើយ ទីបំផុតនៃជីវិតដែលរង់ចាំទទួលពួកជនគ្រប់រូប ដែលមានជីវិតរស់នៅដូច្នោះឬ ?—

នាយឆន្នៈក្រាបទូលស្នងថា "នេះហើយជាភាពៈបំផុតដែលបម្រុងទុកសម្រាប់មនុស្សគ្រប់រូប, អ្នកដែលដេកលើគំនរឧសអម្បាញមិញនេះមានរបស់សំណល់សល់ទុកតិចណាស់ សូម្បីសត្វក្អែកដែលកំពុងស្រែក

ឃ្លាន កំមិនចង់ក្រឡេកមើលផង – ពីមុនមក មនុស្សនេះ បេះស៊ី, ផឹក, សើច; ស្រឡាញ់ រស់រានមានជីវិតហើយបេះស្រឡាញ់ជីវិតរបស់ខ្លួន ៗ តមកសម័យក្រោយ ត្រឡប់ប្រែប្រួលយ៉ាងដូចម្តេចទៅ? នរណាដឹងបាន?– ខ្យល់ព្យុះក្នុងព្រៃធំ, ដើរភ្លាត់ជើងធ្លាក់ពីផ្លូវ; បំរូងបំរះក្នុងអណ្តូង; ពស់ចឹក រងាត្រជាក់ ឆ្អឹងត្រី ឬ គ្រឿងធ្លាក់; អស់នេះអាចបំផ្លាញជីវិតឲ្យវិនាសទៅបាន: ហើយមនុស្សក៏ស្លាប់ ៗ ហើយគេលែងដឹងរសជាត; លែងរីករាយ, លែងមានទុក្ខវេទនា, ទោះបីអណ្តាតភ្លើងឆាបឆេះដុតពេញខ្លួន គេក៏ឥតដឹងខ្លួនយ៉ាងណាសោះ សាច់ឈាមត្រូវភ្លើងឆេះគ្រៀមទៅ ទោះបីក្លិនក្រអូបរបស់ខ្លឹមចន្ទន៍ ប្រមុះលែងដឹងក្លិន, មាត់មិនទទួលរសជាតិ, ត្រចៀកលែងទទួលស្តាប់សំឡេង, ភ្នែកលែងទទួលស្គាល់រូបារម្មណ៍ទាំងអស់, ជនជាទីពេញចិត្តរបស់អ្នកស្លាប់ មានតែការយំសោកកន្ទក់កន្ទេញតែឯកឯង ហើយត្រូវតែទំលាយបំផ្លាញរាងកាយនោះទៅ ដើម្បីកុំឲ្យរាងកាយក្លាយជាអាហារដែលគួរអាណោចអាធម្មរបស់ដង្កូវ, កាយដែលតាំងនៅដោយជីវិត ៗ ដែលជាបន្ទៀងខាងក្នុង ៗ នេះឯងជាជោគលាភធម្មតា សម្រាប់សាច់ឈាមរបស់មនុស្ស; ទោះបីអ្នកមានរិទ្ធិតេជះឬខ្សត់ក្រយ៉ាងណាក៏ដោយ ល្អឬអាក្រក់ក៏ដោយ ក៏ត្រូវតែស្លាប់ដូចគ្នាទាំងអស់; ហើយបើពោលតាមពាក្យដែលគេតែងទូន្មានមកនោះ ថាកាលស្លាប់ទៅហើយក៏ត្រូវកើតជា

ចុះទៀតដែលឥតអ្នកណាដឹងជាក់ច្បាស់ថាទៅកើតនៅទីណា ហើយកើតឡើងដូចម្ដេច; នេះឯងហើយ គឺវដ្ដសង្សាររបស់មនុស្សលោក" ។

កាលព្រះសិទ្ធត្ថៈរាជកុមារ ទ្រង់ងើបព្រះភក្ត្រឡើង មានព្រះអស្សុជលហូរជន់ ទតព្រះនេត្រទៅលើផ្ទៃមេឃ ហើយទតមកផែនដី ព្រះទ័យពោរពេញដោយសេចក្ដីមេត្តា ហើយហាក់ដូចទ្រង់ពិចារណាស្រាវជ្រាវរកយោបល់អ្វីមួយដ៏ជ្រាលជ្រៅ ដែលមានជាប់ទាក់ទងរវាងមេឃនឹងផែនដី គឺយោបល់មួយដ៏វិសេសជាក់ស្ដែងដែលមើលមិនឃើញដោយភ្នែក ប៉ុន្តែកាលបើស្រាវជ្រាវក៏អាចនឹងបានជួបប្រទះឃើញ ហើយស្គាល់ជាក់ច្បាស់បាន" ។

គណៈនោះ ទ្រង់មានព្រះអាការកិរិយាដ៏សំរើម ទ្រង់មានព្រះទ័យដ៏ក្រវល់ក្រវាយ ដោយមានព្រះចំណង់ខ្លាំងក្លា សម្បយុត្តដោយមេត្តាករុណាដ៏លើសលុប ហើយមានព្រះទ័យដ៏ជឿជាក់ក្នុងសេចក្ដីសង្ឃឹមគ្មានទីបំផុត ទាំងមិនសោះសូន្យ ទើបទ្រង់បន្លឺព្រះឧទានវាចាថា "ឱ! លោកវដ្ដកម្ម! ឱ! បងប្អូនទាំងឡាយ ទាំងស្គាល់គ្នា ទាំងមិនដែលស្គាល់គ្នា សុទ្ធសឹងជាប់ជំពាក់នៅក្នុងសំណាញ់ទុក្ខវេទនា នឹងមរណៈទេតើ! យើងឃើញ យើងដឹងក្នុងហេតុនៃការវិវត្តរបស់ផែនដីហើយ; អំនួតនៃសេចក្ដីរីករាយ, ការបោកប្រាសនៃសេចក្ដីសុខសប្បាយ, ការញាប់ញ័រឈឺចាប់នឹងការទុក្ខព្រួយ, សេចក្ដីក្រេមក្រាន្តផុត

អស់ទៅ កាលបើទៅជួបប្រទះនឹងទុក្ខព្រួយ, វ័យក្មេងផុតរលត់ទៅ កាលទៅជួបនឹងចាស់ជរា, សេចក្ដីស្នេហាធ្វើឲ្យកើតទុក្ខ កាលបើព្រាត់ប្រាសរបស់ស្នេហានោះទៅ, កើតហើយក៏មានស្លាប់ កាលស្លាប់ទៅក៏ត្រឡប់កើតឡើងវិញទៀត ដែលធ្វើឲ្យមនុស្សធ្វើដំណើរជាថ្មីទៀត ក្នុងកងកាំនៃសំសារចក្រ ដើម្បីឲ្យវិលវល់ក្នុងរង្វង់នៃសេចក្ដីសប្បាយដែលមិនទៀង នឹងសេចក្ដីទុក្ខព្រួយដ៏ទៀងទាត់ប៉ុណ្ណោះ ។ ខ្លួនយើងនេះក៏ដូចគ្នាដែរ យើងត្រូវគេបញ្ឆោតដោយនុយតាមទំនងនេះ ។ ឯជីវិតហាក់ដូចជាកូនជាទីស្នេហារបស់យើង ហើយមានទំនងដូចជាខ្សែទឹកកណ្ដាលថ្ងៃ ដែលហូរទៅជានិច្ចនិរន្តរ៍ ក្នុងសេចក្ដីស្ងប់ឥតកករល្អក់ ប៉ុន្តែទន្លេដែលហូរកាត់ទីដ៏ដេរដាសដោយផ្កាដ៏ក្រអូបក៏ដោយ តែនៅទីបំផុតទឹកថ្លាយង់ដូចជាកញ្ចក់ ក៏ហូរយ៉ាងរួសរាន់ចូលទៅក្នុងសមុទ្រដ៏មានរសប្រៃមិនបរិសុទ្ធនោះឯង ។ បង្កូតទូកដែលធ្វើឲ្យយើងខ្វាក់ងងិតនេះវិនាសអន្តរាយអស់ហើយ ។ ខ្លួនយើងនេះ ក៏ដូចជាមនុស្សទាំងអស់ក្នុងលោក ដែលនាំគ្នាបួងសួងអង្វរអស់លោកទេព្ដា តែលោកឥតស្ដាប់សោះ ។ ប៉ុន្តែទុកជាយ៉ាងណាក៏ដោយ ត្រូវមានវិធីណាមួយសម្រាប់ជួយអ្នកដទៃនឹងខ្លួនយើង នឹងពួកជនដែលត្រូវការជំនួយអំពីយើង ! ប្រហែលពួកទេព្ដា ក៏ត្រូវកាជំនួយតាមទំនងនេះដែរ ! ចុះហេតុអ្វីក៏អស់លោកទន់ខ្សោយម៉្លេះ មិនអាចជួយស្រោចស្រង់អ្នករងគ្រោះថ្នាក់ដែលគ្នាខំបួង

សូនីអន្ទ័រ! យើងមិនចង់បណ្ដោយឲ្យជនដែលយើងអាចជួយសង្គ្រោះបាន ឲ្យនៅតែទ្រហោយំទេ! ចុះហេតុម្ដេចបានជាព្រះព្រហ្មទ្រង់បានកសាងលោកនេះឡើងហើយបណ្ដោយឲ្យធ្លាក់ទៅក្នុងភ័យអន្តរាយដូច្នេះ? ប្រសិនបើលោកជាអ្នកមានឫទ្ធិមែន មិនរាប់ថាជាអ្នកសប្បុរសទេ ហើយខ្លួនលោកក៏មិនមែនជាព្រះពិតៗផង?- នាយឆន្ន យើងល្មមត្រឡប់ទៅដំណាក់វិញហើយ? ខ្ញុំបានឃើញរឿងរ៉ាវល្មមសមគួរដែរហើយ!" ។

កាលព្រះបាទសម្ដេចព្រះវរបិតា ទ្រង់បានជ្រាបហេតុកេតដូច្នោះ ទ្រង់ចាត់ឲ្យមានពួកយាមរក្សាទ្វារព្រះរាជវាំង ថែមបីគាត់ឡើងទៀត ហើយទ្រង់ចេញព្រះរាជប្រកាសហាមផ្ដាច់ មិនឲ្យជនណាមួយចូលឬចេញ មិនថាយប់មិនថាថ្ងៃ ដរាបទាល់តែផុតកំណត់ថ្ងៃ ដែលទ្រង់បានជ្រាបក្នុងព្រះសុបិននិមិត្តនោះ ។

វគ្គទី ៤

ប៉ុន្តែដល់ថ្ងៃកំណត់ ដែលព្រះជាម្ចាស់នៃយើងទ្រង់ចេញទ្រង់ព្រះផ្នួសនោះ គេបានព្រួសស្រស័ព្ទយំសោកកន្ទក់កន្ទេញ ក្នុងប្រាសាទរាជវាំង ទាំងមហាក្សត្រជាព្រះវររាជបិតា ក៏ទ្រង់ក្សេកខ្សួលរំជួលព្រះហឫទ័យជាខ្លាំង ថែមទាំងអាណាប្រជាជនក្នុងប្រទេសទាំងមូលក៏យំសោកស្ដាយទាំងអស់គ្នា ប៉ុន្តែព្រះរាជដំណើរនេះជាបច្ច័យនាំឲ្យសត្វលោកទួទៅរួចផុតចាកកងទុក្ខទាំងពួង ហើយពួកជនដែលបានស្ដាប់ព្រះធម៌របស់ព្រះអង្គក៏អាចដោះខ្លួនឲ្យផុតរបូតចាកតណ្ហាបានផង ។ (មានត)

## មុនីកាសិត

## មហា "ឱម-ណាគ្រី"

ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង រៀបរៀង,

(តមក)

.........

## ពាលបណ្ឌិតវគ្គ

ពាលំ ន បស្សេ ន សុណេ ន ច ពាលេន សំវសេ

ពាលេហាល្លាបសល្លាបំ ន ករេ ន ច រោចយេ ។

មិនគួរបង់ឃើញ មិនគួរបង់ស្ដាប់ មិនគួរសេពគប់ មិនគួរសន្ទនា

មិនគួរស្មាគមនឹងក្រុមពាលា មិនគួរឲ្យរាប់ចូលចិត្តស្និទ្ធផង ។

ន ចាបជនសំសេវី ឧច្ចុត្តំ សុខមេធតិ

អនត្ថាយេវ វត្តន្តិ ពាលំ អច្ចុបសេវតោ ។

អ្នកដែលមិនសេពគប់នឹងបាបជន តែងបានសុខសន្តិលើសលុន-

ពេកណាស់ ។

បាបគ្រោះចង្រៃសេចក្ដីវិនាស តែងកើនប្រទះអ្នកគប់ពាលពេក ។

ន សន្ធិំ កាបុរិសន កយិរា

អសន្តោ ចាបជនេន សេយ្យោ

មិនគួរធ្វើសេចក្ដីស្រឡាញ់ស្និទ្ធ ជាមួយជាមិត្រមនុស្សអាក្រក់

ការមិនសេពគប់មនុស្សតក់ម៉ក់. គឺមនុស្សអាក្រក់ប្រសើរជាង ។

ពាលសង្គតចារី ហិ · ទីឃមទ្ធាន សោចតិ ·

អ្នកដែលសន្និទ្ធនឹងក្រុមពាលខ្លៅ តែងសោយសោកសៅម្លូរម៉ៅសស្រែង
អស់កាលយូរយារវេលាអង្វែង ទុក្ខទោសលើសលែងលើសលប់
លើសលន់ ។

ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា

ការនៅរួមមិត្តស្និទ្ធនឹងជនពាល បណ្ដាលឲ្យកើតទុក្ខទោសម្លូរម៉ៅ
សព្វទិនទិវាជានិរន្តរ៍ទៅ ដូចនៅជាមួយសត្រូវសាមាន្យ ។

ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ

ការនៅរួមមិត្តស្និទ្ធនឹងអ្នកប្រាជ្ញ តែងអាចបណ្ដាលឲ្យកើតសុខសាន្ត
ដូចនៅជាមួយពួកញាតិសន្តាន ដែលតែងរាប់អានស្មោះស្ម័គ្រមេត្រី ។

យោ ពាលោ សេវតិ សោ វិនាសំ ធារុណាតិ

នរណាសេពគប់គប់នឹងពាលខ្លៅ នរនោះដល់នូវវិនាសជាក់
ហិនហែហិនហោចខូចត្រីហិត: ហេតុនេះលោកអ្នកត្រូវវៀសវៀសវាង ។

យំ វេ សេវតិ តាទិសោ

បើយើងសេពគប់គប់នឹងនរណា កិរិយានៃយើងក៏ដូចនរនោះ
បើគប់នឹងពាលក៏ពាលទាំងអស់ បើគប់សប្បុរសក៏សប្បុរសដែរ ។

និហីយតិ បុរិសោ និហីនសេវី ន ច ហាយេថ

តុល្យសេវី

សេដ្ឋមុបនមំ ឧទេតិ តស្មា អត្តនោ ឧត្តរិំ ភជេថ ។

គប់ជនអាក្រក់តែងអាក្រក់ចុះ គប់មនុស្សស្មើគ្នាតែងមិនវិនាស
គប់ជនប្រសើរជាងតែងខ្ពង់ខ្ពស់ ហេតុនោះគួរគប់ជនគ្រាន់ជាងខ្លួន ។

តក្កកស្ស វិសំ ទន្តោ មក្ខិកាយ វិសំ សិរេ
វិច្ឆិកស្ស វិសំ បុច្ឆេ សព្វង្គំ ទុជ្ជនេ វិសំ ។

ពស់មានចង្កូមជាពិសទ្រឹស្តមហន្ត រុយពិសសំខាន់មាននៅត្រង់ក្បាល
ខ្យមានពិសកណ្តាលខ្លួនឫទ្ធិមហិមា ឯទុជ្ជនពាលាពិសរាលនៅសព៌ាង្គ ។

អទស្សនេន ពាលានំ និច្ចមេវ សុខី សិយា

ជនមានសេចក្តីសុខសាន្តជានិច្ច ព្រោះមិនទង្គិចជួបប្រទះពាល
ជាអ្នកអាក្រក់លាមកពាសពល ជាអ្នកបណ្តាលទុក្ខទោសពៀរភ័យ

ហន្ទាហំ ហាតចក្ខុស្មិ កន្តារទ្ធានមាគតោ
មរិស្សាមិ នោ គមិស្សាមិ នត្ថិ ពាលេ សហាយតា ។

ថ្វី ! បើអញមានចក្ខុខ្វាក់ មកកាន់កន្តារៈមគ្គា
អញស៊ូរតែស្លាប់វេទនា អញមិនទៅជាមួយឯងទេ ។
ព្រោះថាសហាយតាគុណ មិនមានក្នុងជនជាពាលេ
ឯងជាសំឡាញ់អញក៏ទេ ព្រោះឯងវៀចវេលាមកណាស់ ។

សចេ លភេថ និបកំ សហាយំ

សទ្ធិំចរំ សាធុវិហារិ ធីរំ

អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតីមា ។
នោ ចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិ ធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។
ឯកស្ស ចរិតំ សេយ្យោ នត្ថិ ពាលេ សហាយតា
ឯកោ ចរេ ន ច បាបានិ កយិរា
អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។

បើបុគ្គលបានមិត្តសំឡាញ់ មានចិត្តគួបកាញ់ស្និទ្ធស្នេហា
ជាមិត្តប្រកបដោយបញ្ញា សម្រាប់រក្សានូវចិត្តកាយ ។
ជាអ្នកប្រាជ្ញដែលមានព្រះធម៌ ជាគ្រឿងអំពរណ៍នៅសប្បាយ
ត្រូវទៅជាមួយមិនឃ្លាតឆ្ងាយ សង្កត់អន្តរាយគ្រប់យ៉ាងបាន ។
ជាអ្នកត្រេកអរដោយមេត្រី មានស្មារតីមានវិញ្ញាណ
គប្បីត្រូវទៅកុំឲ្យខាន ជាមួយកល្យាណមិត្តនោះចុះ ។
បើមិនបានមិត្តដ៏ករម្យ ស័ក្តិសមឧត្តមគុណដូច្នោះ
គឺមិត្តអាក្រក់មានចិត្តទ្រុស្ត គួរវៀរចាកចុះល្អជាជាង ។
បុគ្គលនោះគួរតែត្រូវទៅ សំដៅទីណាតែម្នាក់ឯង

ប្រៀបដូចមហាក្សត្រិយ៍លះកន្ទេង  គឺដែនស្ដេចស្ដែងទ្រង់មានជ័យ ៗ
ហើយទ្រង់ត្រេចទៅតែឯកោ  គតោសំដៅទីដទៃ
ឬប្រៀបដូចជាដំរីថ្ងៃ  ត្រេចទៅក្នុងព្រៃតែឯកអង្គ ៗ
ការដែលបុគ្គលតែឯកកាយ  ត្រេចទៅជិតឆ្ងាយតាមចំណង់
ហៅពេញប្រសើរយ៉ាងខ្ពស់ខ្ពង់  ព្រោះវង្សបុគ្គលពាលសាមាន្យ ៗ
មិនដែលមានសហាយតា  គុណឯណាមួយក្នុងសន្តាន
និងត្រេចជាមួយផងពុំបាន  ព្រោះវាមិនមានគុណខ្ពង់ខ្ពស់ ៗ
បុគ្គលត្រេចទៅតែម្នាក់ឯង  ប្រសើរក្រៃលែងពិតដូច្នោះ
តែគួរកុំធ្វើបាបឲ្យសោះ  ទើបឈ្មោះថាត្រេចទៅប្រពៃ ៗ
ប្រៀបដូចហត្ថិនាគខ្វល់ខ្វាយតិច  ត្រេចទៅតែម្នាក់ឯងក្នុងព្រៃ
បុគ្គលគួរធ្វើយ៉ាងនេះនៃ  ទើបបានសេចក្ដីចំរើនអើយ ៗ

សធា សមេតិ សតានំ  សមេតិ អសតា អសំ
វាយសោ កុណបំ យាតិ  កុសុមំ យាតិ ឆប្បទេ ៗ

ក្នុងកាលទាំងពួង

សប្បុរសតែងទៅសមាគម  ជាមួយពួកក្រុមសប្បុរស
ដូចភមរជាតិតែងស្ម័គ្រស្មោះ  ត្រេចត្រោះទៅរកផ្កានានា ៗ
ឯអសប្បុរសពាលលោខ្លៅ  នាំទៅអសប្បុរសដូចគ្នា
ទៅកាន់សមាគមសភា  ដូចជាក្អែកត្រេចរកសាកសព ៗ

បរស្ស ហរតោ ពាលោ បរំ ទុគ្គតិគាមិតោ
បរស្ស ទាយកោ ធីរោ បរំ សុគតិគាមិតោ ។

ជនពាលលួចយកទ្រព្យអ្នកដទៃ   រមែងជួបភ័យក្នុងលោកខាងមុខ
គឺត្រូវទៅកើតក្នុងកំណើតទុក្ខ   ប្រេតឬនរកទាំងតិរច្ឆាន ។
ចំណែកឯជនដែលជាអ្នកប្រាជ្ញ   លោកអាចចំណាយបាយលះធនធាន
ដល់ជនដទៃលៃធ្វើជាទាន   តែងទៅកាន់ស្ថានសុគតិភព ។

ន វេ កទរិយា ទេវលោកំ វជន្តិ ពាលា ហវេ នប្បសំសន្តិ
ទានំ ធីរោច ទានំ អនុមោទមានោ តេនេវ សោ ហោតិ
សុខី បរត្ថ

ជនពាលមិនដែលសរសើរទាន   ជនពាលតែងមានចិត្តស្វាញស្វិត
ទៅកាន់ទេវលោកមិនបានពិត   ចំណែកបណ្ឌិតមានប្រាជ្ញា
ទើបអនុមោទនាទាន   លោករមែងបានឋានសុខា
ក្នុងលោកខាងនាយព្រោះតែការ   អនុមោទនាទាននោះឯង ។

យស្មឹ បាបានិ កម្មានិ   ស វេ កណ្ហោតិ វុច្ចតិ

បាបកម្មមាននៅក្នុងចិត្តនរណា   នរនោះឈ្មោះថាជាមនុស្សខ្មៅ
ជាមនុស្សខ្មោចជាមនុស្សពៅ   ជាមនុស្សខ្មៅជាមនុស្សស្រេខ ។

សុករានិ អសាធូនិ   អត្តនោ អហិតានិ ច
យំ វេ ហិតញ្ច សាធុញ្ច   តំ វេ បរមទុក្ករំ ។

អំពើឯណាមិនល្អផង ដែលជាគន្លងនៃអបាយ
មិនមានប្រយោជន៍ដល់ចិត្តកាយ អំពើទាំងឡាយនោះឯងណា ។
ជនពាលតែងធ្វើបានដោយងាយ តែកម្មឆោមឆាយល្អថ្លៃថ្លា
មិនមានប្រយោជន៍ដល់អាត្មា ជនពាលមិច្ឆាធ្វើបានក្រ ។

សុករំ សាធុនា សាធុ សាធុ បាបេន ទុក្ករំ
បាបំ បាបេន សុករំ បាបមរិយេហិ ទុក្ករំ ។

អំពើល្អធម៌សុចរិត សាធុបណ្ឌិតធ្វើបានងាយ
កល្យាណកម្មពាលទាំងឡាយ ខ្វល់ខ្វាយធ្វើបានដោយក្រក្រៃ
អំពើបាបជនបាបសាមាន្យ ធ្វើបានដោយងាយស្រួលកៃខ
បាបកម្មលាមកល្អក់ចង្រៃ ព្រះអរិយៈធ្វើបានក្រ ។

## អវសានភាសិតនៃពាលបណ្ឌិតវគ្គ

គប់ប្រាជ្ញនាំប្រាណឲ្យបានសុខ គប់ពាលនាំស្កុកទុក្ខមកសង
គប់ប្រាជ្ញនាំឃ្លាតចាកបាបផង គប់ពាលសៅហ្មងជាប្រក្រតី ។
គប់ប្រាជ្ញនាំប្រាណទៅស្ថានសួគ៌ គប់ពាលនាំតួទៅអវិចី
គប់ប្រាជ្ញនាំប្រាណឲ្យបានថ្លៃ គប់ពាលចង្រៃនាំថោកទាប ។
គប់ប្រាជ្ញនាំប្រាណឲ្យធ្វើបុណ្យ គប់ពាលទុជ៌ននាំធ្វើបាប
គប់ប្រាជ្ញនាំប្រាណឲ្យបានសុភាព គប់ពាលថោកទាបនាំហឺហា ។
គប់ប្រាជ្ញនាំប្រាណរក្សាសីល គប់ពាលខូចខិលនាំផឹកស្រា

គប់ប្រាជ្ញនាំប្រាណបានអាចារ្យ   គប់ពាលមិច្ឆាកើតអាចោរ ។
គប់ប្រាជ្ញនាំប្រាណឲ្យបានប្រាជ្ញ   គប់ពាលអាចនាំឲ្យពាលោ
គប់ប្រាជ្ញនាំចិត្តគិតត្រូវធម៌   គប់ពាលនាំវរចិត្តគិតខុស ។
គប់ប្រាជ្ញនាំចំរើនប្រយោជន៍   គប់ពាលនាំហោចហិនហែចុះ
គប់ប្រាជ្ញនាំឲ្យសាមគ្គីស្មោះ   គប់ពាលចិត្តទ្រុស្តនាំបែកបាក់ ។
គប់ប្រាជ្ញនាំឲ្យចេះអត់ធន់   គប់ពាលទុជ៌ននាំកាប់ចាក់
គប់ប្រាជ្ញនាំឲ្យចេះទុកដាក់   គប់ពាលអប្បលក្ខណ៍នាំខ្វះខ្វាយ ។
គប់ប្រាជ្ញនាំប្រាណខ្ពស់ជានិច្ច   គប់ពាលនាំលិចលង់អន្តរាយ
គប់ប្រាជ្ញនាំទៅនិព្វាននាយ   គប់ពាលនាំទៅអបាយភូមិ ។

ចប់ពាលបណ្ឌិតវគ្គ

## បញ្ញាបវគ្គ

**សព្វបាបស្ស អករណំ   កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ   ឯតំ ពុទ្ធានសាសនំ ។**

ការមិនធ្វើបាបគ្រប់បែបយ៉ាង   ការសាងបំពេញកុសលវត្ត
ការជុសខាត់ចិត្តស្អាតម៉ត់ចត់   ទាំងនេះជាបទពុទ្ធសាសនា ។

(នៅមានត)

# ពិធីបុណ្យស្រោចទឹក

# លោកគ្រូអាចារ្យ ហង្ស-ប៉េង

ដែលបានឡើងឋានៈជាចៅអធិការទីឯអនុគណ វត្តសិរីសុទ្ធារង្ស ឃុំ-ស្រុក-ខេត្ត-ក្រចេះ •

---

កាលពីថ្ងៃ ៧-៨-៩ កើតខែអាសាធ ឆ្នាំឆ្លូវឯកស័ក ព. ស. ២៤៩២ ត្រូវនឹងថ្ងៃ ២-៣-៤ កក្កដា គ.ស. ១៩៤៩ មានរៀបធ្វើបុណ្យស្រោចទឹកប្រគេនលោកគ្រូអាចារ្យ ហង្ស-ប៉េង ដែលបានឡើងឋានន្តរៈថ្មី ជាចៅ-អធិការទីឯអនុគណ សម្រាប់ស្រុកក្រចេះ ខេត្តក្រចេះ មានសមណ-ស័ក្តិជាព្រះគ្រូសីលគន្ធប្បដ្ឋាគ ។

## របៀបរៀបចំ

មានសាលាបុណ្យប្រក់ក្បឿងគ្រឿងឈើទំហំបណ្តោយ ១៤ ម៉ែត្រ ទទឹង ១០ ម៉ែត្រ ដែលប្រតិស្ឋានពីខាងទក្សិណនៃព្រះវិហារចំមុខព្រះចេតីយធំ ។ តួសាលានោះសឹងមានរំភាយសំពត់ជីតនឹងផ្កាភ្ញីព័ទ្ធជុំវិញ ហើយតែងស្លឹកឈើមានពណ៌ក្រហម-ស-ខៀវ-បៃតងស្រស់ប្រិមប្រិយ៍, ស្រោបសសរទឹងផ្តោងផ្ទាំងសព្វអន្លើ ចងពិតានតែងជារំយោលព្យួរសំយុងចុះរយោងរយានត្រង់ចន្លោះៗ គ្រប់ល្វែងទាំងអស់គួរឲ្យអ្នកផងចាប់ចិត្តចង់មើលហើយមើលទៀត ព្រមទាំងដោតទង់ជាតិខ្មែរ-បារាំងអមតាមលំដាប់ផ្លូវទាំងនោះ ដើម្បីជាកិត្តិយសនៃពិធីបុណ្យ ។ នៅចំចន្លោះនៃ

ព្រះវិហារនឹងសាលានោះ មានតាក់តែងពនម៉ា ៤ ជាន់កំពស់ ៣ ម៉. ៥០ ទ្រង់ទ្រាយជាបុស្សបុក មានកំពូលស្រួចខ្ពស់សម្រាប់ព្រះគ្រុសីលគន្ធប្ប-ផ្លោតស្រង់ទឹក មានជណ្ដើរពីរដាក់ទន្ទឹមគ្នា, ពីខាងកើតសម្រាប់ព្រះសង្ឃនឹងមន្ត្រីខែត្រ ឡើងទៅស្រោចគន្ធវារិ ។ តួពនម៉ានោះសឹងពាសសំពត់សពណ៌ជុំវិញទាំង ៤ ថ្នាក់, ក្នុងថ្នាក់នីមួយៗមានរបងក្បាច់ចាក់បេករលេបពណ៌ជាគ្រឿងលំអ ប៉ាំងរនាំងសុំទ្វារគ្រប់មុខទ្វារទាំង ៤ តាមជួរសសរ, ពីខាងលើសឹងពាសពិតានសំពត់សចងរំយោលផ្កា, រៀបផើងផ្កាជាគូៗត្រង់ជើងពនម៉ាទាំង ៤ ជាន់ គួរជាទីរីករាយ ។ ឯថ្នាក់ទី ៣ ពនម៉ាមានដំកល់កែវទឹក១បាត្រទឹក៤ដែលដាក់សុគន្ធវារី សម្រាប់តស្បរជនស្រោចទឹកទៅលើព្រះគ្រុសីលគន្ធប្បផ្លោត ដែលគង់នៅក្នុងបុស្សបុកឈមព្រះភក្ត្រទៅឯបច្ចិមទិស ទទួលពរជ័យ ។ ព្រះសង្ឃសូត្រជយន្តោប្រគេនពេលនោះ ។ មានទីសីទនដ្ឋាន ១ ទៀត នៅពីខាងទិសអគ្នេយ៍ពនម៉ាដែលមានប្រដាប់ដោយកៅអីតម្រៀបជាជួរៗ សម្រាប់ព្រះសង្ឃគង់សូត្រជយន្តោ ។ ប៉ារាំ ១ ទៀតនៅខាងលិចមុខពនម៉ា សម្រាប់មន្ត្រីខែត្រ ។ រោងប៉ារាំ ១ ទៀតនៅពីខាងពាយ័ព្យពនម៉ា សម្រាប់ទទួលបរិស័ទអ្នកមានសទ្ធាចូលបុណ្យ ។ ក្នុងប៉ារាំទាំង ៣ នេះមានរបៀបតាក់តែងស្រដៀងសាលាបុណ្យនោះដែរ ។

# កម្មវិធីបុណ្យ

ថ្ងៃទី១ម៉ោង២០ថ្ងៃសៅរ៍៧កើតខែអាសាឍ ត្រូវនឹងថ្ងៃ២កក្កដាឆ្នាំ ១៩៤៩, ជួបជុំពុទ្ធបរិស័ទ្យច្រើនណែនណាន់តាន់តាប់នៅសាលាបុណ្យ ទឹងលានវត្ត ធ្វើនមស្ការចំពោះព្រះរតនត្រ័យ រួចនិមន្តព្រះសង្ឃ ៣០ អង្គចំរើនព្រះបរិត្ត ផ្សាយសំឡេងដោយឧគ្ឃោសនសព្ទ ឮគឹកកងរំពងសព្ទសាយពេញទីអាកាស ។ ម៉ោង១១ និមន្តធម្មកថិកសំដែងធម៌ទេសនា យ៉ាងពីរោះក្បោះក្បាយ អំពីធម្មកថាជាច្រើនទឹងរបៀបបុណ្យស្រោចទឹក លុះចប់ទេសនាក៏មានលេងល្បែងជាលំដាប់ហូរហែតទៅ ។

ថ្ងៃទី ២ ម៉ោង ៨ ព្រឹកពួកពុទ្ធបរិស័ទ្យចាត់ចែងយាគូប្រគេនព្រះសង្ឃ ៧៥ អង្គ ដែលនិមន្តមកពីវត្តក្រៅទឹងក្នុងវត្ត, ដល់ម៉ោង ១១ អង្គាសបង្ហាន់ព្រះសង្ឃ ។ ម៉ោង ១៧ ប្រគេនភេសជ្ជៈដល់ព្រះសង្ឃចំនួនដដែល ម៉ោង ២០ មានរបៀបចាត់ចែងដូចថ្ងៃទី ១ ។

ថ្ងៃទី ៣ ម៉ោង ៨ ចាត់ចែងយាគូប្រគេនព្រះសង្ឃ ៧៥ អង្គ រួចហើយជួបជុំបរិស័ទ្យ រៀបពិធីទទួលលោកចៅហ្វាយខែត្រ-ស្រុក ដែលអញ្ជើញមកជាអធិបតីក្នុងឱកាសបុណ្យ, ដល់ម៉ោង ៩,១៥ មីនុតពេលព្រឹក ៩ កើត ព្រះទេពសត្ថា សូ-ហាយ ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ, សូត្រសុន្ទរកថា បន្ទាប់ពីនោះព្រះសាសនមុនីមាស-កង ចៅអធិការវត្តពិភទូរង្សី ក្រុងភ្នំពេញ នឹងលោកចៅហ្វាយខែត្រ និមន្ត

នីងអញ្ជើញឡើងលើកនមោ ស្រោចទឹកសុគន្ធវារីទៅលើព្រះគ្រូសីលគន្ធ-
ប្បជោត, តពីនោះមានលោកគ្រូចៅអធិការចំនួន ១៧ វត្ត ដែលនិមន្ត
មកអំពីវត្តក្រៅ នឹងមន្ត្រីខែត្រ-ស្រុក ឡើងស្រោចជាលំដាប់តទៅ ។
ព្រះសង្ឃក៏សូត្រជយន្តោជាច្រើនចប់ក្នុងពេលនោះ លុះរួចកិច្ចស្រោច
ទឹកហើយ ទើបលោកចៅហ្វាយខែត្រប្រគេនសញ្ញាប័ត្រតាំងពីរចំពោះ
ទៅព្រះគ្រូសីលគន្ធប្បជោត ហង្ស-ប៉េង រូបលោកក៏មានប្រសាសន៍
ប្រគេនពរ ព្រមតាំងប្រកាសដល់ព្រះសង្ឃនិងគ្រហស្ថអំពីកិច្ចតាំង
ចៅអធិការនិងអនុគណដោយសង្ខេប ។

ម៉ោង ១១ អង្គាសចង្ហាន់ចំពោះព្រះសង្ឃ ៧៥ អង្គជាកិច្ចបង្ហើយបុណ្យ
សម្រេចក្នុងពេលនោះ ។

## សុន្ទរកថា ទី ១

ព្រះករុណា តាំងឡាយគ្រប់អង្គ !

ព្រះតេជព្រះគុណចៅហ្វាយខែត្រ !

អស់លោក-អ្នកសប្បុរសទាំងឡាយ !

ខ្ញុំព្រះករុណាអាត្មាភាពតាំងពីររូបនេះ នៅឯក្រុងភ្នំពេញ បានមក
កាន់ពិធីបុណ្យស្រោចទឹកនេះ ដោយកិច្ចនិមន្តនៃពុទ្ធបរិស័ទ្យមកជំនួស
ព្រះតេជព្រះគុណព្រះសង្ឃនាយក ដើម្បីជាក់ស្តែងក្នុងពិធីបុណ្យទទួល
អំណរចំពោះព្រះគ្រូសីលគន្ធប្បជោតអនុគណស្រុកនេះ ដែលទើបនឹង
បានឋានៈជាចៅអធិការ, ជាអនុគណថ្មី ។

អាត្មាភាពទាំងពីររូបនេះ ឈ្មោះថាជាតំណាងព្រះនាមព្រះមហាសុមេធាធិបតីសង្ឃនាយកមកបំពេញកិច្ចបុណ្យនេះ ដោយការណ៍ពិសេស ។ ខ្ញុំព្រះករុណា អាត្មាភាពបានមកឃើញពិធីបុណ្យនេះ ដែលពួកពុទ្ធបរិសទ្យជើងវត្ត បានរៀបចំបុណ្យនេះឲ្យមានរបៀបរៀបរយល្អ មានកម្មវិធីដ៏ប្រសើរ ដែលគួរសរសើរដោយពិត ។

លោកគ្រូអាចារ្យ ហង្ស-ប៉េង ដែលបានឡើងឋានៈជាចៅអធិការ, ជាអនុគណ ក៏ដោយអំណាចសេចក្ដីខ្នះខ្នែងរបស់ព្រះតេជព្រះគុណចៅហ្វាយខេត្តនឹងចៅហ្វាយស្រុក ដែលបានចាត់ចែងតាមផ្លូវការដោយសេចក្ដីស្រុះស្រួលអំពីពុទ្ធបរិសទ្យជើងវត្ត ។ ក្នុងពេលនេះព្រះតេជព្រះគុណចៅហ្វាយខេត្ត ចៅហ្វាយស្រុកក៏ឆ្លៀតរកឱកាសអញ្ជើញមកកាន់ពិធីបុណ្យនេះ ដោយការសំដែងមិត្តភាពចំពោះពុទ្ធបរិសទ្យផង ដើម្បីជួយឈឺឆ្អាលបំពេញករណីយកិច្ចបុណ្យនេះផង ។ ការបុណ្យនេះឈ្មោះថាជាកិត្តិយស ១ ដ៏ប្រសើររបស់ព្រះតេជព្រះគុណចៅហ្វាយខេត្ត ដែលគួរចំណាំទុកក្នុងចិត្តយ៉ាងជាក់លាក់ថា "លោកគ្រូអាចារ្យអង្គនេះដែលបានទីជាចៅអធិការ, ជាអនុគណ ព្រមទាំងកិច្ចបុណ្យនេះ គឺនៅក្នុងជំនាន់កាលដែលព្រះតេជព្រះគុណចៅហ្វាយខេត្ត ចៅហ្វាយស្រុកមកឈរនៅខេត្តនេះ" ។

កុងនុកាសបុណ្យនេះទៀតក៏ព្រះតេជព្រះគុណ មានអធ្យាស្រ័យទុកដាក់បានចាត់ការឲ្យលោកអ្នកក្រុមនគរបាលមកថែរក្សា សន្តិសុខរៀបរយផង ។

អាត្មាភាពទាំងពីររូប ដែលមកពីកុំពេញឃើញការនេះក៏មានចិត្តត្រេកអរសាទរជាទីបំផុត ។

សូមជូនពរ ៤ ប្រការ ចំពោះព្រះតេជព្រះគុណនឹងអស់លោកអ្នកមន្ត្រីគ្រប់គ្នាសូមឲ្យបានចំណែកបុណ្យនេះស្មើៗគ្នា ។

# អំពីតាំងចៅអធិការថ្មី

(តមក)

សញ្ញាប័ត្រលេខ ២៦៣ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ ផុក-គេង នាមឆាយា ឥន្ទជោត កើតឆ្នាំរោង អាយុ ៤៥ វស្សា ២៤ ជាចៅអធិការវត្តកំពង់សាលា ឃុំរបេក ស្រុកបាភ្នំ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ២៦៤ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ កែ-ម៉ោល នាមឆាយា ធម្មសារ កើតឆ្នាំរកា អាយុ ៥៣ វស្សា ៣៣ ជាគ្រូសូត្រស្តាំ វត្តបល្ល័ង្ក ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

សញ្ញាប័ត្រលេខ ២៦៥ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ ឆាយ-លឿង នាមឆាយា សទ្ធម្មប្បញ្ញោ កើតឆ្នាំរកា អាយុ ៥៣ វស្សា ៣២ ជាគ្រូសូត្រឆ្វេងនៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៦៦ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ ឈាង - សាម នាមឆាយា កេសរសិរិយសត្ថេរ កើតឆ្នាំមមី អាយុ ៥៥ វស្សា ៣២ ជាចៅអធិការវត្តពោធិវន ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ២៦៧ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ អ៊ុំ-ផេង នាមឆាយា ជោតសទ្ធម្មត្ថេរ កើតឆ្នាំកុរ អាយុ ៥០ វស្សា ៣០ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៦៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទូច - ឆៃហេង នាមធាយា កេសរជោត កើតឆ្នាំកុរ អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រឆ្វេងនៅវត្ត ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៦៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុម - ឌុន នាមធាយា មង្គលជោត កើតឆ្នាំរកា អាយុ ៤០ វស្សា ១៥ ជាចៅអធិការវត្តញាណពោធិ ឃុំឫស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ២៧០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កែវ - ថោង នាមធាយា ព្រហ្មត្ថេរ កើតឆ្នាំកុរ អាយុ ៥០ វស្សា ២៨ ជាចៅអធិការវត្តល្វើន ឃុំល្វើន ស្រុកស្វាយរៀង ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៧១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ុម - នួន នាមធាយា ចន្ទត្ថេរ កើតឆ្នាំឆ្លូវ អាយុ ៤៨ វស្សា ២៥ ជាគ្រូសូត្រស្តាំ នៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៧២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ៅ - កែន នាមធាយា យសត្ថេរកើតឆ្នាំថោះអាយុ ៤៦ វស្សា ២៥ជា គ្រូសូត្រឆ្វេង នៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៧៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស - ហ៊ុម នាមធាយា ធម្មជោត កើតឆ្នាំរក អាយុ ២៩ វស្សា ៨ ជា

ចៅអធិការវត្តពោធិ៍ដមន្ត្រី ឃុំប្រសូត ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៧៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-សែម នាមឆាយា ចន្ទត្ថេរ អាយុ ៣០ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្ត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៧៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មុំម-អុក នាមឆាយា តន្ទត្ថេរ អាយុ ២៧ វស្សា ៦ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៧៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទិត-តន នាមឆាយា ធម្មប្បញ្ញោ អាយុ ៥៤ វស្សា ៣៤ជាចៅអធិការ វត្តព្រៃធ្នក ឃុំស្វាយតាយាន ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៧៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទិត-យូ នាមឆាយា សុវណ្ណត្ថេរ អាយុ ៣០ វស្សា ៨ ជាគ្រូសូត្រ ស្តាំ នៅវត្ត-ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៧៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ម-ខាត់ នាមឆាយាធម្មនន្ទោអាយុ ២៤ វស្សា ៤ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៧៩ ចុះថ្ងៃចន្ទ ១០ កើតខែកត្តិកឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូជុំ-ធោម នាមឆាយាសុវណ្ណត្ថេរ កើតឆ្នាំខាលអាយុ

៤៧ វស្សា ២៥ ជាចៅអធិការវត្តពោធិ៍បន្ទាយ ឃុំប្រសូត ស្រុកស្វាយទាបខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៨០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចិន-ស្រី នាមឆាយា សុវណ្ណសរ កើតឆ្នាំរកា អាយុ ២៩ វស្សា ៩ ជាចៅអធិការវត្តព្រៃអង្គ ឃុំប្រសូតស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៨១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-ធាំ នាមឆាយាសុវណ្ណជោត កើតឆ្នាំខាល អាយុ ២៣ វស្សា ៣ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក-ដដែល ។

សញ្ញាប័ត្រលេខ ២៨២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ា-ហុង នាមឆាយា ឥន្ទត្ថេរ កើតឆ្នាំម្សាញ់ អាយុ ៣២ វស្សា ១១ជាចៅ-អធិការ វត្តព្រៃអង្គុញ ឃុំប្រកម្ទេស ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៨៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឈុន-ផង នាមឆាយា មង្គលសរ កើតឆ្នាំម្សាញ់ អាយុ ៣២ វស្សា ១១ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៨៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម-គោន នាមឆាយា មង្គលត្ថេរ អាយុ ២៦ វស្សា ៦ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៨៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូវណ្ណ-ថន នាមធាយា ធម្មគុត្ត អាយុ ៣៧ វស្សា ១៥ ជាចៅអធិការវត្តព្រៃគគីរ ឃុំព្រៃគគីរ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៨៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូសួរ-វង់ នាមធាយា សុវណ្ណគុត្ត កើតឆ្នាំឆោះ អាយុ ៣៤ វស្សា ១៣ ជាគ្រូសូត្រស្តាំ នៅវត្ត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៨៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូគិម-កែន អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៨៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូចាន់-ហៃម នាមធាយា ចន្ទោភោ កើតឆ្នាំ ១៩២២ អាយុ ២៦ វស្សា ៥ ជាចៅអធិការ វត្តព្រៃម្នាស់ ឃុំសំឡី ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៨៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូសួរ-ង៉ាន់ នាមធាយា ញាណសំវរោ កើតឆ្នាំ ១៩២២ អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៩០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូឡឹក-សារី នាមធាយាធម្មគុត្ត កើតឆ្នាំ ១៩២៧អាយុ ២២ វស្សា ២ ជាគ្រូសូត្រឆ្វេង នៅវត្តឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៩១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូគង់-យូរ នាមឆាយា វត្តត្ថេរ កើតឆ្នាំច អាយុ ៥១ វស្សា ៣០ ជាចៅអធិការវត្តតាប៉ោ ឃុំសំឡី ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៩២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូស្រី-យ៉ែម នាមឆាយា ធម្មជោតោ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ--ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៩៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូថែន-យាង នាមឆាយា ធម្មបណ្ឌិតោ កើតឆ្នាំខាល អាយុ ២៣ វស្សា ៣ ជាគ្រូសូត្រឆ្វេង នៅវត្តឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៩៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូព្រាប-មឿង នាមឆាយា តន្ទត្ថេរោ កើតឆ្នាំមមែ អាយុ ៤២ វស្សា ២២ ជាចៅអធិការវត្តព្រៃខ្វូត ឃុំប្រែស ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២៩៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូអុក-អ៊ូនាមឆាយា សុវណ្ណប្បញ្ញោ កើតឆ្នាំម្សាញ់ អាយុ ៣២ វស្សា ១១ ជាគ្រូសូត្រស្តាំនៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៩៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូគង់-ថៅ នាមឆាយា សីលវិសុទ្ធោ កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រឆ្វេង នៅវត្តឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៩៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី-អៀង នាមធាយា សិក្ខានន្ទោ កើតឆ្នាំរកា អាយុ ២៩ វស្សា ៧ ជាចៅអធិការ វត្តជ័យរតនៈ ឃុំជ្រាប ស្រុកសន្ទុក ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ២៩៨ ចុះថ្ងៃសុក្រ ១៤ កើតខែភទ្របទឆ្នាំជូត សំរិទ្ធិស័ក តាំងលោកគ្រូ ស្វាយ-អ៊ិម នាមធាយា វជិរប្បញ្ញោ កើតឆ្នាំកុរ អាយុ ៥០ វស្សា ២៩ ជាចៅអធិការ វត្តសំពៅមាស ឃុំលេខ ៥ ក្រុងភ្នំពេញ ។

សញ្ញាប័ត្រលេខ ២៩៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ដៃ-ម៉ៃ នាមធាយា មេធាធិធម្ម កើតឆ្នាំមមែ អាយុ ៤២ វស្សា ២០ ជាគ្រូសូត្រស្តាំនៅវត្ត-ឃុំ-ក្រុងដដែល ។

សញ្ញាប័ត្រលេខ ៣០០ ចុះថ្ងៃចន្ទ ២ រោចខែភទ្របទឆ្នាំជូតសំ-រិទ្ធិស័ក តាំងលោកគ្រូ គិម-អ៊ីង នាមធាយា ឥន្ទធម្មត្ថេរ កើតឆ្នាំរោង អាយុ ៥៧ វស្សា ៣២ ជាចៅអធិការ វត្តអម្ពវនារាម ឃុំស្វាយសាច់ភ្នំ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៣០១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យង់-កែក នាមធាយា ឥន្ទជោត កើតឆ្នាំរោង អាយុ ៣៣ វស្សា ១១ ជាចៅអធិការ វត្តស្វាយអៀ ឃុំចំណារ ស្រុកស្ទោង ខេត្តកំពង់ធំ ។

(មានត)